ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# យុទ្ធសាស្ត្រ
# ស្តីពី
# ការរស់នៅតាមគន្លងប្រក្រតីភាពថ្មី
# ក្នុងបរិបទនៃជំងឺកូវីដ-១៩

រៀបចំដោយគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០២១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១០៩ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់នូវយុទ្ធសាស្ត្រស្តីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២១/៧៥៣ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- យោងតាមតម្រូវការចាំបាច់

# សម្រេច

**ប្រការ១ ..**

ត្រូវបានដាក់ឱ្យប្រើប្រាស់នូវ "**យុទ្ធសាស្ត្រស្ដីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩**" ដែលជាឧបសម្ព័ន្ធនៃសេចក្ដីសម្រេចនេះ។

**ប្រការ២ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៨កើត ខែកត្ដិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## អារម្ភកថា

វិបត្តិនៃជំងឺកូវីដ-១៩ បាន និងកំពុងបន្តដាក់សម្ពាធ លើសុខភាពសាធារណៈ, ប្រព័ន្ធសុខាភិបាល, ការរស់នៅ និងការចូលរួមក្នុងសកម្មភាពសង្គម-សេដ្ឋកិច្ច របស់ប្រជាជនកម្ពុជា។ មេរោគកូវីដ-១៩ ត្រូវបានរំពឹងថានឹងនៅបន្តមានវត្តមាន ក្នុងរយៈពេលវែង និងក្លាយជាផ្នែកមួយនៃការរស់នៅរបស់មនុស្សជាតិ ដូចជាប្រភេទមេរោគគ្រុនផ្តាសាយដទៃទៀតដែរ ។ ក្នុងន័យនេះ, ប្រទេសនីមួយៗ ចាំបាច់ត្រូវសម្រប, បន្សាំខ្លួន និងរៀនរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩ ដើម្បីកាត់បន្ថយផលប៉ះពាល់លើសកម្មភាពសង្គម-សេដ្ឋកិច្ច ឱ្យបានជាអតិបរមា និងធានាបាននូវវិបុលភាព និងសុវត្ថិភាពជូនប្រជាជន និងសង្គមជាតិទាំងមូល ។

សម្រាប់កម្ពុជា, ដើម្បីអាចរស់នៅបានជាមួយនឹងជំងឺកូវីដ-១៩ ប្រកបដោយសុវត្ថិភាព និងសុខុមាលភាព, រាជរដ្ឋាភិបាលបានកំណត់យកការចាក់វ៉ាក់សាំងជាយុទ្ធសាស្ត្រគន្លឹះ សំដៅបង្កើតឱ្យបាននូវភាពស៊ាំសហគមន៍នៅទូទាំងកម្ពុជា គួបផ្សំជាមួយនឹងវិធានការ និងយុទ្ធសាស្ត្រសំខាន់ៗផ្សេងទៀត ក្នុងគោលបំណងការពារអាយុជីវិតរបស់ប្រជាជន, កាត់បន្ថយការឆ្លងរាលដាល និងផលប៉ះពាល់មកលើសង្គម-សេដ្ឋកិច្ច ព្រមទាំងពង្រឹងសមត្ថភាពប្រព័ន្ធសុខាភិបាល ក្នុងការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ ឬជំងឺឆ្លងកាចសាហាវស្រដៀងគ្នាផ្សេងទៀត ដែលអាចកើតមានឡើង ជាយថាហេតុ នាពេលអនាគត ។

ជាមួយនឹងស្មារតីបុរេសកម្ម និងទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តវិធានការ និងយុទ្ធសាស្ត្រ, ដោយមានការចូលរួមយ៉ាងសស្រាក់សស្រាំពីសាធារណជនពីគ្រប់មជ្ឈដ្ឋាន និងការគាំទ្រពីប្រទេសជាមិត្ត និងដៃគូអភិវឌ្ឍន៍, រាជរដ្ឋាភិបាលកម្ពុជា អាចម្ចាស់ការគ្រប់គ្រងបានល្អនូវហានិភ័យនៃជំងឺកូវីដ-១៩ ។ ជាក់ស្តែង, គិតមកត្រឹមថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០២១, កម្ពុជា សម្រេចបានអត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងប្រមាណ ៨៧,៧% នៃចំនួនប្រជាជនសរុបប្រមាណ ១៦ លាននាក់ ហើយចំនួនករណីវិជ្ជមាន និងករណីស្លាប់ ដោយសារជំងឺកូវីដ-១៩ មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ ។ ទន្ទឹមនឹងនេះ, ប្រជាជនកម្ពុជាក៏មានការយល់ដឹងកាន់តែច្បាស់អំពីរបៀបការពារខ្លួនពីជំងឺកូវីដ-១៩ ហើយបាន និងកំពុងផ្លាស់ប្តូរឥរិយាបថនៃការរស់នៅប្រចាំថ្ងៃ តាមគន្លងប្រក្រតីភាពថ្មី ដើម្បីសម្របខ្លួនទៅនឹងជំងឺនេះ ។ ស្របពេលជាមួយគ្នា, ឱសថកាន់តែមានប្រសិទ្ធភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ ត្រូវបានពិភពលោករកឃើញបន្តបន្ទាប់ ហើយដែលកម្ពុជានឹងទទួលបានឱសថទាំងនេះ សម្រាប់ប្រើប្រាស់ផងដែរ នាពេលខាងមុខ ។ សមិទ្ធផលទាំងនេះ បានបង្កើតនូវមូលដ្ឋានរឹងមាំ ដែលបញ្ជាក់ថា ខណៈនេះ គឺជាកាលៈទេសៈមួយដ៏សមស្រប សម្រាប់រាជរដ្ឋាភិបាលប្រកាសពីការរស់នៅជាមួយជំងឺកូវីដ-១៩ និងការបើកប្រទេសឡើងវិញ លើគ្រប់វិស័យ ជាបណ្តើរៗ សំដៅស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ តាមគន្លងប្រក្រតីភាពថ្មី ប្រកបដោយភាពជឿជាក់ និងសុទិដ្ឋិនិយម ចាប់ពីថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០២១ តទៅ ។ ជាមួយគ្នានេះ, ការដាក់ចេញនូវ **យុទ្ធសាស្ត្រស្តីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩** នឹងបំពេញបន្ថែមទៅលើសមិទ្ធផលដែលសម្រេចបានកន្លងមក និងវឌ្ឍនភាពដែលកំពុងមាន ហើយក៏ជាឯកសារសំខាន់មួយដ៏សំខាន់សម្រាប់បង្ហាញផ្លូវ និងធានាភាពធន់សហគមន៍ទៅនឹងជំងឺកូវីដ-១៩ ដើម្បីកម្ពុជាចាប់ផ្តើមចាកចេញពីវិបត្តិនៃជំងឺកូវីដ-១៩ ឆ្ពោះទៅរកមាគ៌ានៃកំណើន និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឡើងវិញ ប្រកបដោយ

សុវត្ថិភាព, ចីរភាព និងបរិយាប័ន្ន ដោយរក្សាបាននូវតុល្យភាពជាមួយនឹងតម្រូវការក្នុងការការពារសុខភាព-សាធារណៈ និងអាយុជីវិតរបស់ប្រជាជន ។

ក្នុងនាមជាប្រមុខរាជរដ្ឋាភិបាល និងជាប្រធាន**គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩** (គ.ប.ក.), ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ **អនុគណៈកម្មការវាយតម្លៃ, ផែនការ និងយុទ្ធសាស្ត្រ** នៃ**គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**(គ.អ.ក.), គណៈប្រតិបត្តិនៃ **គ.អ.ក.** ព្រមទាំងថ្នាក់ដឹកនាំ, ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈប្រតិបត្តិនៃ **គ.អ.ក.** ទទួលបន្ទុកអនុគណៈកម្មការវាយតម្លៃ, ផែនការ និងយុទ្ធសាស្ត្រ, ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណៈប្រតិបត្តិនៃ **គ.អ.ក.** និង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈប្រចាំការនៃ **គ.ប.ក.** ដែលបានរៀបចំ **យុទ្ធសាស្ត្រស្តីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩** ដ៏មានសារៈសំខាន់នេះឡើង ។ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ចំពោះឯកឧត្តម, លោកជំទាវ, លោក និងលោកស្រី ជាប្រធាន, អនុប្រធាន និងសមាជិកនៃក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមក្នុងការរៀបចំយុទ្ធសាស្ត្រនេះឡើង ប្រកបដោយគុណភាព និងប្រសិទ្ធភាព ក្នុងស្មារតីបុរេសកម្ម និងសាមគ្គីភាពខ្ពស់ ។

ខ្ញុំសូមអំពាវនាវឱ្យក្រសួង-ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ប្រកាន់ខ្ជាប់ខ្ជួននូវឆន្ទៈទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្ត **យុទ្ធសាស្ត្រស្តីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩** ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីការពារសុខភាពសាធារណៈ និងអាយុជីវិតប្រជាជន ព្រមទាំងគាំទ្រ និងលើកស្ទួយជីវភាពរបស់ប្រជាជន តាមគន្លងប្រក្រតីភាពថ្មីនេះ ។ លើសពីនេះ, ខ្ញុំសូមអំពាវនាវឱ្យប្រជាជន, ធុរជន និងភ្ញៀវទេសចរទាំងអស់ ដែលស្នាក់អាស្រ័យនៅកម្ពុជា ចូលរួមយ៉ាងសកម្ម ក្នុងការការពារសុវត្ថិភាពផ្ទាល់ខ្លួន និងមនុស្សជុំវិញខ្លួន ដោយបន្តអនុវត្តនូវរាល់វិធានការសុខាភិបាល និងវិធានការចាំបាច់នានាដែលបានដាក់ចេញ និងប្រកាន់ខ្ជាប់នូវ "៣ ការពារ ៣ កុំ" ដើម្បីឱ្យដំណើរឆ្ពោះ ទៅកាន់ការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩ នេះ ប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ, សុវត្ថិភាព, សុខុមាលភាព, វិបុលភាព និងចីរភាព ។

*ថ្ងៃព្រហស្បតិ៍ ៧ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥*
*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០២១*

**នាយករដ្ឋមន្ត្រី**
**និងជាប្រធានគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# មាតិកា

**១. សេចក្តីផ្តើម** ........ ១

១.១. សារបាន ........ ១

១.២. សន្និទានកម្ម ........ ២

១.៣. គន្លងប្រក្រតីភាពថ្មី ........ ៣

**២. ក្របខណ្ឌយុទ្ធសាស្ត្រ** ........ ៤

២.១. ចក្ខុវិស័យ ........ ៤

២.២. គោលបំណង និងគោលដៅ ........ ៤

២.៣. អាទិភាពជាយុទ្ធសាស្ត្រ ........ ៥

២.៤. គោលការណ៍ ........ ៦

**៣. ការអនុវត្ត, តាមដាន និងវាយតម្លៃ** ........ ១០

៣.១. យន្តការទទួលខុសត្រូវលើការអនុវត្ត, ការតាមដាន និងការវាយតម្លៃនៅកម្រិតគោលនយោបាយ និងយុទ្ធសាស្ត្រ ........ ១០

៣.២. យន្តការទទួលខុសត្រូវលើការអនុវត្ត, ការតាមដាន និងការវាយតម្លៃ នៅកម្រិតបច្ចេកទេស និងប្រតិបត្តិ ........ ១០

៣.៣. យន្តការអនុវត្តយុទ្ធសាស្ត្រ ........ ១១

៣.៤. យន្តការតាមដាន និងវាយតម្លៃ ........ ១២

៣.៥. សូចនាករសម្រាប់ការតាមដាន និងការវាយតម្លៃការអនុវត្ត ........ ១៣

**៤. ការកែលម្អ និងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រ** ........ ១៤

**៥. សេចក្តីសន្និដ្ឋាន** ........ ១៥

**បរិសិដ្ឋ** ........ ១៦

បរិសិដ្ឋទី១. សាវតារនៃការប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅកម្ពុជា ........ ១៦

បរិសិដ្ឋទី២. សមត្ថភាពនៃប្រព័ន្ធសុខាភិបាល ........ ២១

បរិសិដ្ឋទី៣. ភាពស៊ាំសហគមន៍ប្រឆាំងនឹងមេរោគកូវីដ-១៩ ........ ២៣

បរិសិដ្ឋទី៤. ការវាយតម្លៃកម្រិតហានិភ័យលើសុខភាពសាធារណៈនៃជំងឺកូវីដ-១៩ ........ ២៤

បរិសិដ្ឋទី៥. ក្របខណ្ឌបច្ចេកទេសសម្រាប់រៀបចំ និងអនុវត្តផែនការសកម្មភាព ........ ២៨

# ១. សេចក្ដីផ្ដើម

## ១.១. សារបាន

ចាប់តាំងពីមានការផ្ទុះឡើងដំបូងនៅចុងឆ្នាំ ២០១៩, ជំងឺកូវីដ-១៩បានឆ្លងរាលដាលនៅតាមបណ្ដាប្រទេសនានានៅលើសកលលោក ដែលបណ្ដាលឱ្យមនុស្សជាង ២៤៨ លាននាក់ ឆ្លងជំងឺ និងជាង ៥ លាននាក់បាត់បង់អាយុជីវិត ។ រហូតមកដល់ពេលបច្ចុប្បន្ននេះ, វិបត្តិនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរមកលើសង្គម-សេដ្ឋកិច្ចនៃសកលលោក ហើយកំពុងបន្តបង្កនូវភាពមិនប្រាកដប្រជា និងហានិភ័យខ្ពស់ ដោយសាររលកថ្មីនៃការបំប្លែងខ្លួនថ្មីនៃមេរោគកូវីដ-១៩ ដែលអាចមានសមត្ថភាពចម្លងកាន់តែលឿន និងអាចមានសភាពកាន់តែកាចសាហាវ ព្រមទាំងបន្តបង្កនូវផលប៉ះពាល់ដល់សកម្មភាពសង្គម-សេដ្ឋកិច្ចទូទៅ ។ ជាក់ស្ដែង, នៅក្នុងក្របខណ្ឌតំបន់, មេរោគបំប្លែងថ្មីបាន និងកំពុងធ្វើឱ្យប្រទេសមួយចំនួនដែលធ្លាប់គ្រប់គ្រងករណីឆ្លងបានល្អ ក្លាយជាតំបន់ក្ដៅគគុកនៃការឆ្លងរាលដាលនៃជំងឺនេះ ។

កម្ពុជា ក៏បាន និងកំពុងទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីវិបត្តិនៃជំងឺកូវីដ-១៩ នេះដែរ ដោយបានរកឃើញករណី ទី១ នៃជំងឺកូវីដ-១៩ លើអ្នកដំណើរបរទេស ដែលបានធ្វើដំណើរមកកាន់ក្រុងព្រះសីហនុ នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០២០ ។ គិតមកត្រឹមថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០២១, ប្រជាជនកម្ពុជាសរុបចំនួន ១១៩.៣៥៨ នាក់ បានឆ្លងជំងឺ, ១១៥.៧៣០ នាក់ បានជាសះស្បើយ, ២.៨៥០ នាក់បានបាត់បង់ជីវិត និង៧៧៨ នាក់ កំពុងសម្រាកព្យាបាល ។ ទោះជាយ៉ាងនេះក៏ដោយ, ជាមួយនឹងការប្ដូរផ្ដាច់ក្នុងការការពារសុខភាពសាធារណៈ និងអាយុជីវិតរបស់ប្រជាជន និងក្នុងស្មារតីបុរេសកម្ម, រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវវិធានការឆ្លើយតបជាបន្តបន្ទាប់ និងអាចរក្សាការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន ។

ជារួម, ការប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅកម្ពុជា អាចចែកចេញជា ៤ ដំណាក់កាលសំខាន់ៗ (សាវតារលម្អិតមាននៅក្នុង បរិសិដ្ឋទី១) ដូចខាងក្រោម ៖

- **ទី១. ដំណាក់កាលនៃការប្រយុទ្ធ និងការទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍** (ចាប់ពីខែ មីនា ឆ្នាំ ២០២០ រហូតដល់ដំណាច់ខែ តុលា ឆ្នាំ ២០២០);
- **ទី២. ដំណាក់កាលនៃការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍** (ចាប់ពីខែ វិច្ឆិកា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២១);
- **ទី៣. ដំណាក់កាលនៃការបង្កើត "ភាពស៊ាំក្នុងសហគមន៍" ប្រឆាំងនឹងជំងឺកូវីដ-១៩ តាមរយៈការអនុវត្តយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ គួបផ្សំជាមួយនឹងការបន្តគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍** (ចាប់ពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២១ រហូតដល់ដំណាច់ខែ តុលា ឆ្នាំ ២០២១); និង

**ទី៤. ដំណាក់កាលនៃការបើកដំណើរការប្រទេសពេញលេញឡើងវិញលើគ្រប់វិស័យ និងការរស់នៅជាមួយជំងឺកូវីដ-១៩ "តាមគន្លងប្រក្រតីភាពថ្មី"** (ចាប់ពីថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០២១ តទៅមុខ) ។

## ១.២. សន្និទានកម្ម

ក្នុងស្មារតីបុរេសកម្ម, ការទទួលខុសត្រូវខ្ពស់ និងចក្ខុវិស័យវែងឆ្ងាយ, រាជរដ្ឋាភិបាលបានសម្រេចរៀបចំយុទ្ធសាស្រ្តមួយ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ សម្រាប់ការរស់នៅ និងបើកដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចឡើងវិញ ជាជំហានៗ តាមគន្លងប្រក្រតីភាពថ្មី ស្របតាមសភាពការណ៍អនុញ្ញាតដោយឈរលើមូលដ្ឋាន ដូចខាងក្រោម៖

**ទី១.** ហេតុមកដល់ពេលនេះ គ្មានប្រទេសណាមួយអាចលុបបំបាត់ជំងឺកូវីដ-១៩ បាន ហើយក៏មិនអាចនឹងវិលត្រលប់មករក "ប្រក្រតីភាពដូចក្នុងអំឡុងពេលមុននៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩" បានដែរ ប៉ុន្តែអាចកាត់បន្ថយការឆ្លង, ការឈឺសម្រាកពេទ្យ, ការបាត់បង់អាយុជីវិត និងការបាត់បង់ផលប្រយោជន៍សង្គម និងកំណើនសេដ្ឋកិច្ច ។

**ទី២.** ការអូសបន្លាយពេលនៃការឆ្លងរាលដាលបានផ្តល់ឱកាសឱ្យមេរោគកូវីដ-១៩ បន្តបំប្លែងខ្លួន និងមានសមត្ថភាពអាចចម្លងកាន់តែលឿន និងកាចសាហាវ និងប្រឆាំងនឹងប្រសិទ្ធភាពវ៉ាក់សាំងបច្ចុប្បន្ន ដែលជាការបញ្ជូនសញ្ញាថា មេរោគកូវីដ-១៩ នឹងបន្តរស់នៅជាមួយមនុស្សក្នុងរយៈពេលយូរតទៅមុខទៀត ។

**ទី៣.** កម្ពុជាសម្រេចជោគជ័យក្នុងយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩, ទាំងដូសមូលដ្ឋាន ទាំងដូសជំរុញ, ដើម្បីបង្កើតបាននូវភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយ។ គិតត្រឹមថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០២១, ប្រជាជនអាយុចាប់ ៦ ឆ្នាំឡើងប្រមាណ ៨៧,៥% នៃចំនួនប្រជាជនក្នុងប្រទេស សរុបប្រមាណ ១៦ លាននាក់ ទទួលបានការចាក់វ៉ាក់សាំងយ៉ាងតិចមួយដូស និងប្រមាណជាង ៨២% នៃប្រជាជនសរុប ទទួលបានការចាក់ដូសមូលដ្ឋាន (ពេញលេញតាមរបបចាក់វ៉ាក់សាំង) ខណៈពេលដែលការចាក់វ៉ាក់សាំងដូសជំរុញបាន និងកំពុងតែបន្ត ។

**ទី៤.** រាជរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចមានការយល់ដឹងកាន់តែច្បាស់ពីយុទ្ធសាស្ត្រដើម្បីបង្ការ, កាត់បន្ថយ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ បច្ចុប្បន្ន, កម្រិតហានិភ័យលើសុខភាពសាធារណៈ កំពុងស្ថិតនៅក្រោមការគ្រប់គ្រងបានល្អ ទោះបីការឆ្លងរាលដាលក្នុងសហគមន៍នៅតែបន្តកើតមានក៏ដោយ ។ ប្រព័ន្ធសុខាភិបាលមានសមត្ថភាព ក្នុងការឆ្លើយតបនឹងការឆ្លងរាលដាល និងក្នុងការផ្តល់សេវាព្យាបាល និងថែទាំ ដោយរាប់បញ្ចូលទាំងសេវាសង្គ្រោះកម្រិតធ្ងន់ (Intensive Care Unit/ICU) ។ ទន្ទឹមនឹងនេះ, រាជរដ្ឋាភិបាលកំពុងស្វះ-

ស្វែងរកឱសថព្យាបាល, បច្ចេកវិទ្យាវេជ្ជសាស្ត្រ និងវិធីសាស្ត្រថ្មីៗ ដើម្បីលើកកម្ពស់គុណភាព, សុវត្ថិភាព និងសក្តិសិទ្ធភាពនៃការព្យាបាល និងថែទាំអ្នកជំងឺ (បរិសិដ្ឋទី២) ។

**ទី៥.** ប្រជាពលរដ្ឋកម្ពុជា បាន និងកំពុងរស់នៅ និងប្រកបកិច្ចការងារ ជាមួយជំងឺកូវីដ-១៩ ហើយសកម្មភាពសង្គម-សេដ្ឋកិច្ច នៃវិស័យ/អនុវិស័យជាអាទិភាពមួយចំនួន ក៏បាន និងកំពុងប្រតិបត្តិការមួយផ្នែក ឬបើកឡើងវិញជាបណ្ដើរៗ ផងដែរ ។ ការណ៍នេះ ផ្ដល់នូវបទពិសោធន៍ជាមូលដ្ឋានសម្រាប់បន្តការរស់នៅ និងប្រតិបត្តិការសកម្មភាពសង្គម-សេដ្ឋកិច្ច តាមគន្លងប្រក្រតីភាពថ្មី នៅពេលបើកប្រទេស និងបើកដំណើរការពេញលេញឡើងវិញនូវសកម្មភាពសង្គម-សេដ្ឋកិច្ច ក្នុងគ្រប់វិស័យទាំងអស់ ។

## ១.៣. គន្លងប្រក្រតីភាពថ្មី

ទោះបីការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បច្ចុប្បន្ន ស្ថិតនៅក្រោមការគ្រប់គ្រងក្ដី ក៏ហានិភ័យនៃការផ្ទុះ និងឆ្លងរាលដាលក្នុងទ្រង់ទ្រាយធំអាចកើតមានជាយថាហេតុ នៅពេលដែលសកម្មភាពសង្គម-សេដ្ឋកិច្ច ត្រូវបានបើកឱ្យដំណើរការឡើងវិញលើគ្រប់វិស័យ ។ ក្នុងន័យនេះ, ប្រជាពលរដ្ឋ, សាធារណជន និងធុរជន ត្រូវរស់នៅ, ប្រកបការងារ, ប្រាស្រ័យទាក់ទងគ្នា និងគ្រប់គ្រងកិច្ចដំណើរការនៃសកម្មភាពសង្គម-សេដ្ឋកិច្ច តាមគន្លងប្រក្រតីភាពថ្មី ឈរលើមូលដ្ឋាននៃនិយាមចាំបាច់ ដូចខាងក្រោម៖

**ទី១.** **ការធានាឱ្យបាននូវភាពស៊ាំសហគមន៍ដ៏រឹងមាំពិតប្រាកដមួយ** តាមរយៈការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសមូលដ្ឋាន និងដូសជំរុញ ឱ្យបានគ្រប់ៗគ្នា តាមរបបចាក់វ៉ាក់សាំង និងពេលវេលា ដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល (បរិសិដ្ឋទី៣) ។

**ទី២.** **ការធានាឱ្យបាននូវសុវត្ថិភាព** ដោយទទួលស្គាល់ថាមេរោគកូវីដ-១៩ កំពុងរស់នៅជាមួយយើង ហើយអាចបណ្ដាលឱ្យធ្លាក់ខ្លួនឈឺ និងបាត់បង់អាយុជីវិត ជាយថាហេតុ ជាពិសេសអ្នកដែលមិនបានចាក់វ៉ាក់សាំង ។ ដូច្នេះ, ទាំងអស់គ្នាត្រូវបន្សាំ, សម្រប និងទម្លាប់រស់នៅ ឬដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ច ដោយសុវត្ថិភាព និងការទទួលខុសត្រូវខ្ពស់ ជាពិសេសត្រូវបង្កើនការប្រុងប្រយ័ត្នខ្ពស់ នៅក្នុងដំណាក់កាលដែលការឆ្លងរាលដាលនៅតែអាចបន្តកើតមាន ។

**ទី៣.** **ភាពបុរេសកម្មក្នុងការបង្ការ និងការគ្រប់គ្រងហានិភ័យ** ដោយតាមដាន និងវាយតម្លៃសភាពការណ៍ជំងឺកូវីដ-១៩ ជាប្រចាំ ដើម្បីត្រៀមលក្ខណៈនិងធ្វើការឆ្លើយតបនឹងការផ្ទុះឆ្លងរាលដាលក្នុងសហគមន៍ និងទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ច ឱ្យបានទាន់ពេល និងមានប្រសិទ្ធភាព ។

# ២. ក្របខណ្ឌយុទ្ធសាស្ត្រ

## ២.១. ចក្ខុវិស័យ

វិបត្តិនៃជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើសុខភាពសាធារណៈ, ប្រព័ន្ធសុខាភិបាល និងសុខុមាលភាពសង្គម-សេដ្ឋកិច្ច ។ ពេលវេលានេះ គឺជាកាលៈទេសៈដ៏សមស្របសម្រាប់កម្ពុជា ក្នុងការបើកប្រទេស និងការបើកដំណើរការឡើងវិញគ្រប់វិស័យសង្គម-សេដ្ឋកិច្ច ដោយសុវត្ថិភាព ក្នុងស្មារតីប្រុងប្រយ័ត្ន, បុរេសកម្ម និងការទទួលខុសត្រូវខ្ពស់ ដើម្បី "**ចាកចេញពីវិបត្តិនៃជំងឺកូវីដ-១៩ ក្នុងភាពរឹងមាំ និងត្រលប់ទៅរកមាគ៌ានៃកំណើន និងការអភិវឌ្ឍ**" ដោយរក្សាបាននូវតុល្យភាពជាមួយនឹងតម្រូវការក្នុងការការពារសុខភាពសាធារណៈ និងអាយុជីវិតរបស់ប្រជាជន ។

## ២.២. គោលបំណង និងគោលដៅ

ដើម្បីឈានឆ្ពោះទៅសម្រេចចក្ខុវិស័យខាងលើ, **យុទ្ធសាស្ត្រ ស្តីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩** ត្រូវបានរៀបចំឡើងក្នុងគោលបំណង "**គ្រប់គ្រងហានិភ័យសុខភាពសាធារណៈ ឱ្យនៅទាបបំផុត (Endemic)**[1] **ជាពិសេសការឆ្លាក់ខ្លួនឈឺ និងការបាត់បង់អាយុជីវិត** ខណៈដែលសកម្មភាពសង្គម-សេដ្ឋកិច្ចនៅក្នុងប្រទេស គ្រប់ផ្នែក-គ្រប់វិស័យត្រូវបានចាប់ផ្តើមបើកដំណើរការពេញ-លេញឡើងវិញជាបណ្តើរៗ ។

ដើម្បីសម្រេចគោលបំណងនេះ, យុទ្ធសាស្ត្របានកំណត់នូវគោលដៅចំនួន ៣ (បី) ដូចខាងក្រោម៖

- **ទី១.** ការពារអាយុជីវិត និងការពារសុវត្ថិភាពក្នុងការរស់នៅ និងក្នុងការចូលរួមរបស់ប្រជាពលរដ្ឋគ្រប់រូប នៅក្នុងសកម្មភាពសង្គម-សេដ្ឋកិច្ច ។
- **ទី២.** ពង្រឹងសមត្ថភាពស្នូលនៃប្រព័ន្ធសុខាភិបាល ដើម្បីបង្ការ និងគ្រប់គ្រងការឆ្លងរាលដាលជំងឺកូវីដ-១៩ ផង និងផ្តល់សេវាសុខាភិបាលជាសារវន្តជាប្រចាំផង ។
- **ទី៣.** រក្សាកិច្ចដំណើរការឡើងវិញនៃសកម្មភាពសង្គម-សេដ្ឋកិច្ច ប្រកបដោយសុវត្ថិភាព និងនិរន្តរ-ភាព ។

[1] Endemic សំដៅដល់ស្ថានភាពដែលមេរោគកូវីដ-១៩ លែងសកម្មក្នុងការចម្លង ប៉ុន្តែមិនមានន័យថា "គ្មានមេរោគកូវីដ-១៩" សោះនោះទេ ឬ អាចនិយាយម្យ៉ាងទៀតថា មេរោគកូវីដ-១៩ គ្មានលទ្ធភាពបង្កឱ្យមានការឆ្លងរាលដាលដូចបច្ចុប្បន្ន ប៉ុន្តែអាចធ្វើឱ្យមនុស្សធ្លាក់ខ្លួនឈឺ និងបាត់បង់អាយុជីវិតបាន ដូចគ្នាជំងឺផ្តាសាយធំដែរ ។

### រូបភាពទី ១. ក្របខណ្ឌនៃយុទ្ធសាស្ត្រ




## ២.៣. អាទិភាពជាយុទ្ធសាស្ត្រ

ដើម្បីសម្រេចគោលបំណង និងគោលដៅខាងលើ, យុទ្ធសាស្ត្រនេះ ផ្តោតលើអាទិភាពចំនួន ៤ (បួន) ដូចខាងក្រោម៖

**ទី១.** លើកកម្ពស់ការទទួលខុសត្រូវរបស់បុគ្គលគ្រប់រូប ក្នុងការរស់នៅ និងក្នុងការចូលរួមក្នុងសកម្មភាពសង្គម-សេដ្ឋកិច្ច តាមគន្លងប្រក្រតីភាពថ្មី ។

**ទី២.** ពង្រឹងប្រព័ន្ធសុខាភិបាលដោយផ្តោតជាចម្បងលើសមត្ថភាពនៃការត្រៀមបម្រុង និងការឆ្លើយ-តបទាន់ពេល ប្រកបដោយប្រសិទ្ធភាព ក្នុងការបង្ការ និងការគ្រប់គ្រងជំងឺកូវីដ-១៩ និងលើសមត្ថភាពនៃការផ្តល់សេវាព្យាបាល និងថែទាំ ជាពិសេសការស្វះស្វែងរកឱសថ, វិធីសាស្ត្រ និងបច្ចេកវេជ្ជសាស្ត្រថ្មី ដែលធានាដល់ការព្យាបាលប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធ-ភាពខ្ពស់ សំដៅការពារសុខភាព និងអាយុជីវិតរបស់ប្រជាពលរដ្ឋ និងរក្សាឱ្យបាននូវនិរន្តរភាពនៃកិច្ចដំណើរការនៃសកម្មភាពសង្គម-សេដ្ឋកិច្ច ។

**ទី៣.** បើកដំណើរការឡើងវិញនូវសកម្មភាពសង្គម-សេដ្ឋកិច្ច ប្រកបដោយសុវត្ថិភាព និងនិរន្តរភាព ដោយភ្ជាប់ជាមួយនឹងវិធានការសុវត្ថិភាព, វិធានការសុខាភិបាល និងវិធានការរដ្ឋបាល សម-ស្របតាមកម្រិតហានិភ័យនៅតាមតំបន់, ទីតាំង និងតាមប្រភេទនៃសកម្មភាពសង្គម-សេដ្ឋ-កិច្ច នីមួយៗ ។

**ទី៤.** តាមដាន និងវាយតម្លៃគ្រប់ជ្រុងជ្រោយជាប្រចាំ នូវសភាពការណ៍នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងផលប៉ះពាល់លើសុខភាពសាធារណៈ, ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសកម្មភាពសង្គម-សេដ្ឋកិច្ច នៅតាមតំបន់ និងទូទាំងប្រទេស ។

## ២.៤. គោលការណ៍

ដើម្បីឈានទៅសម្រេចគោលដៅដែលបានកំណត់, យុទ្ធសាស្ត្រនេះត្រូវបានរៀបចំដោយឈរលើគោលការណ៍ខាងក្រោម៖

**ទី១. ការគ្រប់គ្រងបាននូវហានិភ័យ៖** ការកំណត់បានពីកម្រិតហានិភ័យសុខភាពសាធារណៈនៅតាមតំបន់ភូមិសាស្ត្រ និងហានិភ័យនៃការចម្លងនៅតាមប្រភេទសកម្មភាពសង្គម-សេដ្ឋកិច្ច គឺជាមូលដ្ឋានគ្រឹះសម្រាប់ធ្វើការសម្រេចចិត្តប្រកបដោយវិចារណកម្ម លើការបន្ធូរបន្ថយ ឬរឹត-បន្តឹងមកវិញនូវវិធានការដែលកំពុងអនុវត្ត សំដៅគ្រប់គ្រងសភាពការណ៍ ឱ្យបានទាន់ពេល ។ បរិសិដ្ឋទី៣ ផ្តល់ការពន្យល់បន្ថែមអំពីវិធីកំណត់ហានិភ័យសុខភាពសាធារណៈ ។

**ទី២. ការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ/សាធារណជន និងពីគ្រប់មជ្ឈដ្ឋាន៖** បុគ្គលម្នាក់ៗ, គ្រួសារ, សហគមន៍, សាធារណជនពីគ្រប់មជ្ឈដ្ឋាន, ក្រសួង-ស្ថាប័ន, អង្គភាព, គ្រឹះស្ថាន និងអាជីវកម្ម ក្នុងវិស័យសាធារណៈ និងឯកជន ត្រូវយល់ដឹង និងមានភាពបុរេសកម្ម ក្នុងការបង្ការ និងការគ្រប់គ្រងការឆ្លងរាលដាលនៃមេរោគកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ។

**ទី៣. ការបើកឡើងវិញ ដោយប្រុងប្រយ័ត្ននូវសកម្មភាពសង្គម-សេដ្ឋកិច្ច តាមតំបន់ និងវិស័យ ឬអនុ-វិស័យ៖** ការបើកដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចឡើងវិញ ត្រូវបានរំពឹងថា អាចធ្វើឱ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ គ្រប់ពេល និងគ្រប់ទ្រង់ទ្រាយ ។ ក្នុងន័យនេះ, ការបើកដំណើរការពេញលេញជាបណ្តើរៗ នូវសកម្មភាពសង្គម-សេដ្ឋកិច្ច ត្រូវប្រព្រឹត្តទៅ យ៉ាងម៉ត់ចត់ និងប្រុងប្រយ័ត្នខ្ពស់ តាមអភិក្រម ដូចខាងក្រោម៖

- *ការបើកឡើងវិញស្របតាមសភាពការណ៍អនុញ្ញាត ដោយភាពក្លាហាន និងការទទួលខុស-ត្រូវខ្ពស់៖* ល្បឿននៃការបើកដំណើរការឡើងវិញអាចខុសៗគ្នា ពី តំបន់ និងវិស័យ ឬអនុ-វិស័យ ឬប្រភេទនៃសកម្មភាពសង្គម-សេដ្ឋកិច្ចមួយ ទៅតំបន់ និងវិស័យ ឬអនុវិស័យ ឬប្រភេទនៃសកម្មភាពសង្គម-សេដ្ឋកិច្ចមួយផ្សេងទៀត អាស្រ័យលើកម្រិតហានិភ័យ, ធនធានហេដ្ឋារចនាសម្ព័ន្ធ និងសារៈសំខាន់សម្រាប់ផលប្រយោជន៍សង្គម-សេដ្ឋកិច្ច តាមតំបន់និងវិស័យ ឬអនុវិស័យ និងប្រភេទនៃសកម្មភាពសង្គម-សេដ្ឋកិច្ច។ លើមូលដ្ឋាននេះ, អាទិភាពត្រូវបានផ្តល់ទៅឱ្យវិស័យមួយចំនួនដូចជាវិស័យទេសចរណ៍, កាត់ដេរ-វាយនភណ្ឌ, ឧស្សាហ-កម្ម, កសិកម្ម, អប់រំ និងបណ្តុះបណ្តាលជំនាញ ជាដើម ក្នុងការបើកដំណើរការសកម្មភាពឡើងវិញ ។
- *ការបើកឡើងវិញដោយប្រយ័ត្នប្រយែង ជាជំហានៗ ផ្អែកលើវិសេសភាពនៃតំបន់ ឬវិស័យ ឬអនុវិស័យ ឬប្រភេទនៃសកម្មភាពសង្គម-សេដ្ឋកិច្ច*ដោយផ្សារភ្ជាប់ជាមួយនឹងការអនុវត្តវិធាន

សុវត្ថិភាព និងនីតិវិធីប្រតិបត្តិស្តង់ដារ (SOP) ។ វិធានសុវត្ថិភាព និងនីតិវិធីប្រតិបត្តិស្តង់ដារ ត្រូវធ្វើការកែលម្អជាបន្តបន្ទាប់ ស្របតាមតម្រូវការ និងស្ថានភាពជាក់ស្តែង ។

- *ការរក្សាភាពបត់បែននៃការអនុវត្តវិធាន "បើក/បិទ"* ដោយរក្សា "តុល្យភាព" រវាងផលប្រយោជន៍សុខភាពសាធារណៈ និងផលប្រយោជន៍សង្គម-សេដ្ឋកិច្ច តាមដែលអាចធ្វើបាន។ ដូច្នេះការសម្រេចចិត្តបើកដំណើរការបន្ថែមទៀត ឬរឹតបន្តឹងមកវិញ ត្រូវស្របតាមកម្រិតហានិភ័យនៃសុខភាពសាធារណៈ និងផលប៉ះពាល់លើសង្គម-សេដ្ឋកិច្ច នៃវិស័យ ឬអនុវិស័យ ។ ក្នុងន័យនេះ, នៅមុនពេលធ្វើការសម្រេចចិត្តផ្លាស់ប្តូរ វិធាន *"បើក/បិទ"* ត្រូវកំណត់ឱ្យបានច្បាស់លាស់រវាងតំបន់ដែលមានហានិភ័យទាប និងតំបន់ដែលមានហានិភ័យខ្ពស់, កម្រិតហានិភ័យនៃការចម្លងនៅក្នុងទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ច នៃតំបន់នីមួយៗ ។
- *បុរេលក្ខខណ្ឌ៖* ការបើកដំណើរការឡើងវិញ ត្រូវឈរលើការបំពេញបានជាសារវន្តនូវបុរេលក្ខខណ្ឌសំខាន់ៗ រួមមាន៖ (ទី១). អត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសមូលដ្ឋានយ៉ាងតិច ៨០% នៃប្រជាជនសរុប នៅក្នុងតំបន់ភូមិសាស្ត្រដែលសកម្មភាពសង្គម-សេដ្ឋកិច្ចត្រូវបើកដំណើរឡើងវិញ, (ទី២). ហានិភ័យសុខភាពសាធារណៈ នៅក្នុងតំបន់ភូមិសាស្ត្រនោះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងបាន និង (ទី៣). វិធានសុវត្ថិភាព និងនីតិប្រតិបត្តិស្តង់ដារ ត្រូវបានដាក់ឱ្យដំណើរការរួចជាស្រេចនៅក្នុងទីតាំងនៃសកម្មភាពសង្គម-សេដ្ឋកិច្ចទាំងនោះ ។

**ទី៤. ភាពប្រទាក់ក្រឡាគ្នានៃយុទ្ធសាស្ត្រ៖**

- ***អភិបាលកិច្ចក្នុងប្រព័ន្ធសុខាភិបាល និងប្រព័ន្ធសង្គម-សេដ្ឋកិច្ច៖*** ពង្រឹងការផ្សារភ្ជាប់គ្នារវាង យន្តការ "អភិបាលកិច្ចនៃការគ្រប់គ្រងការឆ្លើយតបនឹងជំងឺកូវីដ-១៩" ជាមួយយន្តការ "អភិបាលកិច្ចនៃការគ្រប់គ្រងការផ្តល់សេវា" ដើម្បីបង្កើនភាពធន់នៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធសង្គម-សេដ្ឋកិច្ច ។
- *ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន/ឌីជីថល ដើម្បីគាំទ្រដល់ប្រព័ន្ធសុខាភិបាល និងប្រព័ន្ធសង្គម-សេដ្ឋកិច្ច* ដើម្បីបង្កើនប្រសិទ្ធភាពនៃ៖ (ទី១). ការតាមដាន និងការវាយតម្លៃហានិភ័យ និងផលប៉ះពាល់, ប្រសិទ្ធភាពនៃការឆ្លើយតប និងអនុលោមភាពនៃការអនុវត្តវិធានសុវត្ថិភាព, នីតិវិធីប្រតិបត្តិស្តង់ដារ និងវិធានការចាំបាច់ដទៃទៀត, (ទី២). ការផ្តល់សេវាសាធារណៈ សំដៅកាត់បន្ថយការជួបប្រាស្រ័យទាក់ទងគ្នាផ្ទាល់ នៅក្នុងសកម្មភាពសង្គម-សេដ្ឋកិច្ច ដែលប្រឈមនឹងហានិភ័យនៃការចម្លងខ្ពស់ និង (ទី៣). ការប្រាស្រ័យទាក់ទងគ្នា និងសកម្មភាពនៃការអប់រំលើកកម្ពស់សុខភាព ។
- *ការធានាអនុលោមភាពនៃការអនុវត្តវិធានការសុខាភិបាល, រដ្ឋបាល និងច្បាប់* ដោយត្រូវពង្រឹងជាប្រចាំនូវអន្តរាគមន៍ដ៏ចាំបាច់ក្នុងការបង្ការ, កាត់បន្ថយ និងគ្រប់គ្រងការចម្លង ជា

ពិសេស នៅតាមតំបន់ភូមិសាស្ត្រ ឬប្រភេទសកម្មភាពសង្គម-សេដ្ឋកិច្ច ដែលមានលក្ខណៈ ប្រមូលផ្តុំមនុស្សច្រើន និងមានហានិភ័យខ្ពស់ នៃការចម្លងជំងឺកូវីដ-១៩ ។

## ២.៥. យុទ្ធសាស្ត្រអនុវត្ត

យុទ្ធសាស្ត្រអនុវត្ត ត្រូវបានរៀបចំឡើង ដូចខាងក្រោម៖

### ទី១. ការពារអាយុជីវិត និងសុវត្ថិភាពនៃការរស់នៅ និងការចូលរួមក្នុងសកម្មភាពសង្គម-សេដ្ឋកិច្ច របស់ប្រជាពលរដ្ឋគ្រប់រូប៖

ទោះបី ហានិភ័យនៃការចម្លងមានកម្រិតទាប ឬអាចគ្រប់គ្រងបានទាំងស្រុង ហើយអត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ មានកម្រិតខ្ពស់ក្តី, ក៏មិនមានន័យថា "សូន្យមេរោគកូវីដ-១៩" ដែរ ។ ជាមួយគ្នានេះ, នៅពេលដែលសកម្មភាពសង្គម-សេដ្ឋកិច្ចចាប់ផ្តើមបើកដំណើរការ, ការប្រាស្រ័យទាក់ទងគ្នារវាងក្រុមបុគ្គល ឬរវាងក្រុមគ្រួសារ ឬក្នុងចំណោមប្រជាពលរដ្ឋទូទៅ ក៏នឹងចាប់ផ្តើមមានសកម្មភាពទូលំទូលាយឡើងវិញ ហើយហានិភ័យនៃការផ្ទុះ និងការឆ្លងរាលដាលនេះ អាចនឹងមានរឹតតែខ្ពស់ នៅតាមទីតាំងដែលប្រមូលផ្តុំមនុស្សច្រើន, បិទជិត ឬគ្មានខ្យល់ចេញ-ចូលគ្រប់គ្រាន់ ។ ក្នុងន័យនេះ, ដើម្បីកាត់បន្ថយហានិភ័យឱ្យបានជាអតិបរមា ទាមទារឱ្យមានការបន្តជំរុញ និងអនុវត្តយុទ្ធសាស្ត្រ ខាងក្រោម៖

- រក្សាភាពស៊ាំសហគមន៍រឹងមាំជាប្រចាំប្រឆាំងនឹងមេរោគកូវីដ-១៩ ជាពិសេសមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មី ។
- តាមដាន, វាយតម្លៃ និងសិក្សាស្រាវជ្រាវអំពីប្រសិទ្ធភាពនៃវ៉ាក់សាំងកូវីដ-១៩ ដើម្បីគាំទ្រដល់ការពិនិត្យកែសម្រួលយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឬវិធានការពាក់ព័ន្ធចាំបាច់នានា ។
- គ្រប់គ្រងការប្រាស្រ័យទាក់ទងគ្នា និងទំនាក់ទំនងសាធារណៈ ប្រកបដោយប្រសិទ្ធភាព និងទាន់ពេល ជាពិសេសក្នុងករណីមានការឆ្លងរាលដាលក្នុងទ្រង់ទ្រាយធំ ។
- ពង្រឹងអនុលោមភាព នៃការអនុវត្តវិធានសុវត្ថិភាព វិធានការសុខាភិបាល រដ្ឋបាល និងច្បាប់ នៅតាមទីតាំងនៃសកម្មភាពសង្គម-សេដ្ឋកិច្ច និងក្នុងសហគមន៍ ។

### ទី២. ពង្រឹងសមត្ថភាពស្នូលនៃប្រព័ន្ធសុខាភិបាល ដើម្បីបង្ការ និងគ្រប់គ្រងការឆ្លងរាលដាលជំងឺកូវីដ-១៩ ផង និងផ្តល់សេវាសុខាភិបាលជាសារវ័ន្តជាប្រចាំផង៖

ភាពធន់នៃប្រព័ន្ធសុខាភិបាល ជាកត្តាគន្លឹះមួយដែលធានាឱ្យការរស់នៅរបស់ប្រជាពលរដ្ឋ និងការបើកដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចពេញលេញ អាចរក្សាបានប្រកបដោយសុវត្ថិភាព និងនិរន្តរភាព ។ ក្នុងបរិការណ៍នេះ, ប្រព័ន្ធសុខាភិបាលត្រូវមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងការឆ្លងរាល-

ដាលនៃជំងឺកូវីដ-១៩ ផង និងការផ្តល់សេវាសុខភាពជាសារវន្ត ជាប្រចាំផង ជាពិសេស សេវាសង្គ្រោះបន្ទាន់ និង ICU តាមរយៈការអនុវត្តយុទ្ធសាស្ត្រ ដូចខាងក្រោម៖

- គ្រប់គ្រងច្រកចេញ-ចូលប្រទេសដោយម៉ត់ចត់ ដើម្បីទប់ស្កាត់ ការនាំចូលមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មី ដែលអាចបំផ្លាញប្រសិទ្ធភាពវ៉ាក់សាំង និងបង្កគ្រោះថ្នាក់កាចសាហាវឆ្លងចូលក្នុងសហគមន៍ ។
- បង្ការ, កាត់បន្ថយ និងគ្រប់គ្រងការផ្ទុះឆ្លងរាលដាលនៅតាមទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ច ព្រមទាំងដាក់វិធានការកាត់បណ្តាញចម្លងពីសហគមន៍មួយ ទៅសហគមន៍មួយទៀត ក្នុងករណីចាំបាច់ ។
- បង្កើនសមត្ថភាពផ្តល់សេវាបង្ការ, សេវាធ្វើរោគវិនិច្ឆ័យ, ព្យាបាល និងថែទាំ ដែលមានគុណភាព, សុវត្ថិភាព និងប្រសិទ្ធភាព ដើម្បីអាចឆ្លើយតបប្រកបដោយប្រសិទ្ធភាព ក្នុងករណីមានការផ្ទុះ និងឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងទ្រង់ទ្រាយធំ ដែលនាំឱ្យកើនឡើងនូវការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ និងការបាត់បង់អាយុជីវិត។
- កសាងភាពជាដៃគូរវាងផ្នែកសាធារណៈ និងឯកជន ក្នុងការលើកកម្ពស់សេវាបង្ការ ព្យាបាល និងថែទាំអ្នកជំងឺកូវីដ-១៩ ដោយឈរលើគោលការណ៍នៃតុល្យភាព រវាងផលប្រយោជន៍សុខភាពសាធារណៈ និងធុរកិច្ច ។

### ទី៣. រក្សាកិច្ចដំណើរការឡើងវិញនៃសកម្មភាពសង្គម-សេដ្ឋកិច្ច ប្រកបដោយសុវត្ថិភាព និងនិរន្តរភាព៖

វិស័យ និងអនុវិស័យទាំងអស់ ត្រូវសម្រប និងកែសម្រួលប្រតិបត្តិការរបស់ខ្លួន តាមគន្លងប្រក្រតីភាពថ្មី ដើម្បីគ្រប់គ្រងហានិភ័យនៃការចម្លង និងឈានឆ្ពោះទៅបើកដំណើរការពេញលេញឡើងវិញ ប្រកបដោយសុវត្ថិភាព និងនិរន្តរភាព ។ ការធានាបាននូវសុវត្ថិភាព និងនិរន្តរភាពនៃកិច្ចដំណើរការពេញលេញ គឺជាការទទួលខុសត្រូវរួមផង និងដោយឡែកផងរបស់វិស័យ និងអនុវិស័យនីមួយៗ និងរបស់សហគមន៍ទាំងមូល ក្នុងការអនុវត្តវិធានការសុវត្ថិភាព និងសុខាភិបាលបានត្រឹមត្រូវ ។ ក្នុងន័យនេះ, ដើម្បីចៀសវាងនូវភាពអាក់រអួលនៃការសកម្មភាពការងារ, ការផ្តល់សេវាកម្ម ឬចង្វាក់ផលិតកម្ម ទាមទារឱ្យអនុវត្តយុទ្ធសាស្ត្រ ខាងក្រោម៖

- បង្ការ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ព្រមទាំងការផ្ទុះឆ្លងរាលដាលតាមទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ច ក្នុងវិស័យ និងអនុវិស័យនីមួយៗ ។
- ការពារមន្ត្រី, បុគ្គលិក, កម្មករ-និយោជិត ព្រមទាំងអតិថិជន ពីហានិភ័យនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។

# ៣. ការអនុវត្ត, តាមដាន និងវាយតម្លៃ

ការធានាឱ្យបាននូវប្រសិទ្ធភាព និងភាពជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រ តម្រូវឱ្យមានការចូលរួមប្រកបដោយស្មារតីម្ចាស់ការ, បុរេសកម្ម និងការទទួលខុសត្រូវខ្ពស់ ពីសំណាក់ក្រសួង-ស្ថាប័ន, រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធទាំងអស់ ដោយរាប់បញ្ចូលទាំងវិស័យឯកជន និងសហគមន៍ ។

## ៣.១. យន្តការទទួលខុសត្រូវលើការអនុវត្ត, ការតាមដាន និងការវាយតម្លៃនៅកម្រិតគោលនយោបាយ និងយុទ្ធសាស្ត្រ

**ទី១. គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ (គ.ប.ក.)**

- កំណត់គោលនយោបាយ និងទិសដៅជាយុទ្ធសាស្ត្រ សំដៅកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់លើសុខភាពសាធារណៈ និងសកម្មភាពសង្គម-សេដ្ឋកិច្ច, គ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩, រក្សាសុវត្ថិភាព និងនិរន្តរភាពក្នុងការរស់នៅរបស់ប្រជាពលរដ្ឋ និងការបើកប្រទេស និងកិច្ចដំណើរការស្តារ និងជំរុញកំណើនសង្គម-សេដ្ឋកិច្ចឡើងវិញ; និង
- ពិនិត្យ និងសម្រេចលើយុទ្ធសាស្ត្រ ឬផែនការសកម្មភាពតាមវិស័យ ឬអនុវិស័យ ។

**ទី២. គណៈប្រចាំការនៃ គ.ប.ក.**

- ដឹកនាំការអនុវត្តយុទ្ធសាស្ត្រ ដោយធានានូវសង្គតិភាព និងភាពប្រទាក់ក្រឡាគ្នា;
- តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ; និង
- រាយការណ៍ជាប្រចាំជូន គ.ប.ក. ដើម្បីពិនិត្យ សម្រេច និងផ្តល់ការណែនាំលើការដាក់ចេញនូវយុទ្ធសាស្ត្រឆ្លើយតបថ្មី ឬសម្រេចបន្តអនុវត្តយុទ្ធសាស្ត្រដែលមានស្រាប់ ស្របតាមស្ថានភាពជាក់ស្តែង នៃហានិភ័យសាធារណៈ និងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។

## ៣.២. យន្តការទទួលខុសត្រូវលើការអនុវត្ត, ការតាមដាន និងការវាយតម្លៃ នៅកម្រិតបច្ចេកទេស និងប្រតិបត្តិ

**ទី១. គណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ (គ.អ.ក.)**

- ដឹកនាំការធ្វើបច្ចុប្បន្នភាពនៃយុទ្ធសាស្ត្រ ជាទៀងទាត់ ស្របតាមស្ថានការណ៍វិវត្តនៃការគ្រប់គ្រងជំងឺកូវីដ-១៩ និងវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រ ឈរលើអភិក្រមនៃការរក្សាយុទ្ធសាស្ត្រនេះ ជា "យុទ្ធសាស្ត្ររស់" ដែលអាចធ្វើបច្ចុប្បន្នភាពបាន និងមានភាពបត់បែនគ្រប់គ្រងសម្រាប់ការអនុវត្ត និងការឆ្លើយតបចំពោះសភាពការណ៍ដែលវិវត្តជានិច្ច ។
- ផ្តល់ការណែនាំបច្ចេកទេស, កៀរគរធនធាន និងសម្របសម្រួលដល់ការអនុវត្ត, ការតាមដាន និងការវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ នៅកម្រិតវិស័យ/អនុវិស័យ និងពហុវិស័យ និង

- ផ្ដល់យោបល់ និងរាយការណ៍ជាប្រចាំ ជូនគណៈប្រចាំការនៃ គ.ប.ក. ដើម្បីពិនិត្យ សម្រេច និងផ្ដល់ការណែនាំ ក្នុងការអនុវត្តយុទ្ធសាស្ត្រ ។

**ទី២. គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត (គ.រ.ខ.)**

- ដឹកនាំការធ្វើបច្ចុប្បន្នភាពនៃផែនការសកម្មភាព របស់រដ្ឋបាលរាជធានី-ខេត្ត ស្របតាមបច្ចុប្បន្នភាព និងស្ថានការណ៍វិវត្តនៃការគ្រប់គ្រងជំងឺកូវីដ-១៩,
- ធ្វើការវាយតម្លៃហានិភ័យសុខភាពសាធារណៈ និងសមត្ថភាពប្រព័ន្ធសុខាភិបាល នៅតាមភូមិសាស្ត្រ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងដាក់ចេញវិធានការ ស្របតាមកម្រិតហានិភ័យជាក់ស្ដែង,
- ដឹកនាំ, ផ្ដល់ការគាំទ្រ និងសម្របសម្រួលការអនុវត្ត និងការតាមដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាព ព្រមទាំងផ្ដល់ការណែនាំដល់អង្គភាព និងរដ្ឋបាលមូលដ្ឋាន ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន សំដៅពង្រឹងប្រសិទ្ធភាពនៃការអនុវត្ត; និង
- រាយការណ៍ជាប្រចាំ ជូនគណៈប្រតិបត្តិ នៃ គ.អ.ក. ដើម្បីពិនិត្យ និងផ្ដល់យោបល់ណែនាំ ។

## ៣.៣. យន្តការអនុវត្តយុទ្ធសាស្ត្រ

**ទី១. ការគាំទ្រដល់ការរៀបចំផែនការសកម្មភាព**

- ក្រសួង-ស្ថាប័នទទួលបន្ទុកវិស័យ/អនុវិស័យនីមួយៗ និងយន្តការស្ថាប័នក្រោមចំណុះ គ.ប.ក. និង គ.អ.ក. ត្រូវផ្ដល់ការគាំទ្របច្ចេកទេស ដល់វិស័យ/អនុវិស័យ និង/ឬ គ.រ.ខ. (ដូចជាគោលការណ៍ណែនាំ ឬឧបករណ៍បច្ចេកទេស ការបណ្ដុះបណ្ដាល ជាដើម) ក្នុងការរៀបចំ និងការអនុវត្តផែនការសកម្មភាព ។

**ទី២. ការរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្ត**

- សាមីក្រសួង-ស្ថាប័ន, អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ, គ្រឹះស្ថាន និងយន្តការពាក់ព័ន្ធក្រោមចំណុះ គ.ប.ក. / គ.អ.ក. ត្រូវរៀបចំ និងអនុវត្តផែនការសកម្មភាពរបស់ខ្លួន ឱ្យមានសង្គតិភាពជាមួយនឹងយុទ្ធសាស្ត្រ / វិធានការជាយុទ្ធសាស្ត្រ ដែលពាក់ព័ន្ធផ្ទាល់ និង/ឬ មានភាពប្រទាក់ក្រឡាគ្នា ជាមួយនឹងវិសេសភាពរបស់ខ្លួន (បរិសិដ្ឋទី៥ ផ្ដល់ឧបករណ៍បច្ចេក-ទេសសម្រាប់ការរៀបចំផែនការសកម្មភាព) ។ ជារួម, ផែនការសកម្មភាព ត្រូវតែបានធ្វើការពិនិត្យ និងកែសម្រួល ស្របតាមការធ្វើបច្ចុប្បន្នភាពនៃយុទ្ធសាស្ត្រ ។

**ទី៣. ការអនុវត្តផែនការសកម្មភាព**

- ក្រសួង-ស្ថាប័នទទួលបន្ទុកវិស័យ/អនុវិស័យនីមួយៗ និងយន្តការស្ថាប័ន ក្រោមចំណុះ គ.ប.ក. / គ.អ.ក. ត្រូវផ្ដល់ការគាំទ្រ និងសម្របសម្រួលដល់ គ.រ.ខ. និងយន្តការពាក់ព័ន្ធ ក្នុងការអនុវត្ត និងការតាមដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាព តាមវិស័យ / អនុ-វិស័យ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ។

- ក្រសួង-ស្ថាប័ន, អង្គភាព, យន្តការពាក់ព័ន្ធចំណុះក្រោម គ.ប.ក./គ.អ.ក., រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានទាំងសាធារណៈ និងឯកជន ត្រូវអនុវត្តផែនការសកម្មភាពរបស់ខ្លួន និងតាមដាន និងវាយតម្លៃការអនុវត្ត ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដោយប្រើប្រាស់ធនធាន និងសម្របសម្រួល/សហការរួមគ្នា ប្រកបដោយប្រសិទ្ធភាព ដើម្បីចូលរួមចំណែកដល់ការសម្រេចជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រ ។

ក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើស្ថាប័នីយកម្មការងាររៀបចំការអនុវត្ត, ការតាមដាន និងការវាយតម្លៃផែនការសកម្មភាព ឬផែនការត្រៀមបម្រុង និងឆ្លើយតបនឹងជំងឺកូវីដ-១៩ នៅក្នុងប្រព័ន្ធផែនការនីយកម្ម និងថវិកានីយកម្មរបស់ខ្លួន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន ជាពិសេស ធនធានមនុស្ស និងហិរញ្ញវត្ថុ និងរក្សាភាពបុរេសកម្ម និងបង្កើនភាពធន់របស់ស្ថាប័ន ដោយមិនគ្រាន់តែទប់ទល់ជាមួយវិបត្តិ ឬផលប៉ះពាល់នៃជំងឺកូវីដ-១៩ ប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រៀមទប់ទល់នឹងជំងឺឆ្លងកាចសាហាវផ្សេងទៀត ដែលអាចផ្ទុះឆ្លងរាលដាល នាពេលអនាគតផងដែរ ។

## ៣.៤. យន្តការតាមដាន និងវាយតម្លៃ

ដោយឯកសារយុទ្ធសាស្ត្រនេះ គឺជាឯកសាររស់, ការអនុវត្តយុទ្ធសាស្ត្រនេះ នឹងត្រូវបានតាមដាន និងវាយតម្លៃជាប្រចាំ ដោយប្រើប្រាស់សូចនាករតាមផ្នែកអន្តរាគមន៍ជាអាទិភាពនីមួយៗ សម្រាប់វាស់វែងវឌ្ឍនភាពនៃការសម្រេចឱ្យបាននូវគោលដៅ និងគោលបំណងយុទ្ធសាស្ត្រដែលបានកំណត់, ព្រមទាំងដាក់ចេញនូវវិធានការអន្តរាគមន៍ឱ្យបានសមស្រប និងទាន់ពេល ចំពោះបញ្ហាប្រឈម និងចំណុចខ្វះខាត ដែលកើតមាន ។ ក្នុងន័យនេះ, ការតាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រនេះ នឹងប្រើប្រាស់នូវយន្តការដែលមានស្រាប់ ដូចជា៖ គ.ប.ក., គ.អ.ក., គ្រប់អនុគណៈកម្មការពាក់ព័ន្ធនានាចំណុះឱ្យ គ.អ.ក. និង គ.រ.ខ. ដែលមានមន្ទីរសុខាភិបាល រាជធានី-ខេត្ត ជាសេនាធិការ ។

យន្តការតាមដាន និងវាយតម្លៃនេះ ត្រូវអនុវត្តឡើងក្នុងទម្រង់បែបបទ ដូចតទៅ៖

**ទី១. ក្រសួង-ស្ថាប័ន, អង្គភាព និងគ្រឹះស្ថានក្នុងវិស័យ ថ្នាក់ជាតិ** អនុវត្តវិធានការយុទ្ធសាស្ត្រ ដូចដែលមានចែងក្នុងក្របខណ្ឌបច្ចេកទេសសម្រាប់ការរៀបចំផែនការសកម្មភាព (បរិសិដ្ឋទី៥) និងធ្វើការរាយការណ៍អំពីវឌ្ឍនភាព ប្រចាំខែ, ត្រីមាស, ឆមាស និងលទ្ធផលប្រចាំឆ្នាំ ជូន **គ.អ.ក.** ។

**ទី២. ស្ថាប័ន, អង្គភាព និងគ្រឹះស្ថាន ថ្នាក់ក្រោមជាតិ** អនុវត្តវិធានការយុទ្ធសាស្ត្រ ដូចដែលមានចែងក្នុងផែនការសកម្មភាព (បរិសិដ្ឋទី៥) និងរាយការណ៍អំពីវឌ្ឍនភាពប្រចាំខែ, ត្រីមាស, ឆមាស និងលទ្ធផលប្រចាំឆ្នាំ ជូន គ.រ.ខ. ។

**ទី៣. គ.រ.ខ.**, ដោយមានមន្ទីរសុខាភិបាលរាជធានី-ខេត្ត ជាសេនាធិការ, ត្រូវទទួលខុសត្រូវក្នុងការតាមដាន និងវាយតម្លៃសូចនាករគន្លឹះនៅថ្នាក់រាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ ហើយរៀបចំធ្វើ

របាយការណ៍វឌ្ឍនភាពប្រចាំខែ, ត្រីមាស, ឆមាស និងលទ្ធផលប្រចាំឆ្នាំ ជូន **គ.អ.ក.** ដែលមានភារកិច្ចរៀបចំរបាយការណ៍រួម និងរាយការណ៍ជូន **គ.ប.ក.** ។

- **គ.អ.ក.** ពិនិត្យរបាយការណ៍វឌ្ឍនភាព និងដាក់ចេញនូវវិធានការអន្តរាគមន៍ដើម្បីដោះស្រាយនូវរាល់បញ្ហានានា ពាក់ព័ន្ធទៅនឹងការអនុវត្តយុទ្ធសាស្ត្រនេះ ។ ជាមួយគ្នានេះ, **គ.អ.ក.** ត្រូវរៀបចំធ្វើរបាយការណ៍រួមនៃវឌ្ឍនភាពប្រចាំខែ, ត្រីមាស, ឆមាស និងលទ្ធផលប្រចាំឆ្នាំ ក៏ដូចជាសំណើដាក់ចេញនូវវិធានការអន្តរាគមន៍នានា ដែលមានចរិតគោលនយោបាយ និង/ឬ នយោបាយ ជូន **គ.ប.ក.** ។
- **គ.ប.ក.** ពិនិត្យរបាយការណ៍រួមនៃវឌ្ឍនភាពប្រចាំខែ, ត្រីមាស, ឆមាស និងលទ្ធផលប្រចាំឆ្នាំរបស់ **គ.អ.ក.** និងផ្តល់អនុសាសន៍ទៅវិញចំពោះវិធានការអន្តរាគមន៍នានា ដែលមានចរិតគោលនយោបាយ និង/ឬ នយោបាយ ។

## ៣.៥. សូចនាករសម្រាប់ការតាមដាន និងការវាយតម្លៃការអនុវត្ត

លទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រ នឹងត្រូវបានធ្វើការតាមដាន និងវាយតម្លៃ ដោយប្រើប្រាស់សូចនាករ ដូចខាងក្រោម:

**ទី១. សូចនាករសុខភាពសាធារណៈ និងសមត្ថភាពប្រព័ន្ធសុខាភិបាល៖**

- អត្រាអ្នកជំងឺកូវីដ-១៩ សម្រាកព្យាបាល
- អត្រាបាត់បង់អាយុជីវិតនៃអ្នកជំងឺកូវីដ-១៩
- អត្រាប្រើប្រាស់គ្រែ ICU នៃអ្នកជំងឺកូវីដ-១៩
- អត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩
- សូចនាករដែលអាចប្រើប្រាស់ជាបន្ថែម មានបញ្ជាក់នៅក្នុងបរិសិដ្ឋទី៣

**ទី២. សូចនាករសុវត្ថិភាព** (proxies)**៖**

- អត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ តាមតំបន់ ឬវិស័យ/អនុវិស័យ ឬតាមប្រភេទសកម្មភាពសង្គម-សេដ្ឋកិច្ច
- ផែនការយុទ្ធសាស្ត្រឬ ផែនការសកម្មភាព ឬផែនទីបង្ហាញផ្លូវសម្រាប់ការបើកដំណើរការឡើងវិញត្រូវបានរៀបចំ និងអនុវត្ត តាមវិសេសភាពនៃវិស័យ ឬអនុវិស័យ ឬប្រភេទសកម្មភាពសង្គម-សេដ្ឋកិច្ច
- ការប្រើប្រាស់ QR Code (Stop-Covid-19) តាមវិសេសភាពនៃវិស័យ/អនុវិស័យ ឬតាមប្រភេទសកម្មភាពសង្គម-សេដ្ឋកិច្ច
- នីតិវិធីប្រតិបត្តិស្តង់ដារ / វិធានសុវត្ថិភាពត្រូវបានរៀបចំ និងអនុវត្ត តាមវិសេសភាពនៃវិស័យ / អនុវិស័យ ឬតាមប្រភេទសកម្មភាពសង្គម-សេដ្ឋកិច្ច
- ហានិភ័យតាមវិសេសភាពនៃវិស័យ/អនុវិស័យ ឬតាមប្រភេទសកម្មភាពសង្គម-សេដ្ឋកិច្ចត្រូវបានវាយតម្លៃ

- អនុលោមភាពនៃការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារ/វិធានសុវត្ថិភាព តាមវិស័យ / អនុ-វិស័យ ឬតាមប្រភេទសកម្មភាពសង្គម-សេដ្ឋកិច្ច (តាមរយៈការធ្វើអង្កេត)
- ការប្រើប្រាស់ QR Code និងការអនុវត្តវិធាន "៣ ការពារ ៣ កុំ" (តាមរយៈការធ្វើអង្កេត) ។

**ប្រភពទិន្នន័យ៖** ការតាមដាន និងវាយតម្លៃ តម្រូវឱ្យប្រើប្រាស់ទិន្នន័យ/ព័ត៌មានទាន់បច្ចុប្បន្នភាព និងមានគុណភាពខ្ពស់ ពីប្រភពដែលអាចជឿទុកចិត្តបាន និងទាក់ទងនឹងវិស័យសុខាភិបាលផង និងវិស័យសង្គម-សេដ្ឋកិច្ចផង ។ ក្រសួង-ស្ថាប័ន, អង្គភាព, គ្រឹះស្ថាន និងយន្តការពាក់ព័ន្ធ ត្រូវប្រមូលទិន្នន័យ/ព័ត៌មានទាក់ទងនឹងសូចនាករក្នុងតារាងខាងលើ យកមកចងក្រង ធ្វើការវិភាគ, បកស្រាយ, រាយការណ៍ ឬផលិតជារបាយការណ៍ សម្រាប់ការប្រើប្រាស់ និងផ្សព្វផ្សាយ ។ ទិន្នន័យ/ព័ត៌មានអាចប្រមូលពីប្រភពដែលមានស្រាប់ និងពីប្រភពផ្សេងទៀតដែលអាចរកបាន ក្នុងនោះរួមមានជាអាទិ៍៖ ប្រព័ន្ធអង្កេតតាមដានជំងឺ, ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល, របាយការណ៍របស់ក្រសួង-ស្ថាប័ន អង្គភាព គ្រឹះស្ថាន យន្តការពាក់ព័ន្ធនានា, របាយការណ៍រដ្ឋបាល ហិរញ្ញវត្ថុ, ការសិក្សាស្រាវជ្រាវ/ការធ្វើអង្កេត, របាយការណ៍អង្កេតប្រជាសាស្ត្រនិងសុខភាព (៥ ឆ្នាំ ម្តង) និងអង្កេតសង្គម-សេដ្ឋកិច្ច (មួយឆ្នាំម្តង), របាយការណ៍ជំរឿនទូទៅប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ជាដើម ។

# ៤. ការកែលម្អ និងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រ

ទោះបីជារាជរដ្ឋាភិបាលកម្ពុជា បានត្រៀមខ្លួនរួចជាស្រេច ក្នុងការបើកដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចពេញលេញឡើងវិញ ជាបណ្តើរៗ ក៏ដោយ, ភាពមិនប្រាកដប្រជា និងភាពមិនអាចប៉ាន់ប្រមាណបាន ក៏នៅតែមាន ដោយមេរោគកូវីដ-១៩ អាចនឹងបំប្លែងខ្លួនជាប្រភេទមេរោគថ្មី ជាបន្តបន្ទាប់ ។ ក្នុងស្មារតីនេះ, **យុទ្ធសាស្ត្រស្តីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩** ត្រូវតែជា **"ឯកសាររស់"** ដោយរាជរដ្ឋាភិបាលត្រូវបន្តត្រួតពិនិត្យ, កែលម្អ និងធ្វើបច្ចុប្បន្នភាពឯកសារនេះ ក្នុងករណីចាំបាច់ ឱ្យស្របតាមស្ថានភាព, ការវិវត្ត និងវឌ្ឍនភាពជាក់ស្តែងនៅក្នុងប្រទេស, តំបន់ និងសកលលោកទាំងមូល ។

# ៥. សេចក្តីសន្និដ្ឋាន

ខណៈដែលបណ្តាប្រទេសនានាក្នុងតំបន់ និងលើសកលលោក បាន និង កំពុងពន្លឿនការចាក់វ៉ាក់សាំង ដើម្បីបង្កើតភាពស៊ាំជូនដល់ប្រជាជនរបស់ខ្លួនឱ្យបានឆាប់ និងជំរុញការបើកកិច្ចដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចពេញលេញ ជាបណ្តើរៗ សំដៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញតាម **«គន្លងប្រក្រតីភាពថ្មី»**, កម្ពុជា ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យច្បាស់លាស់ និងស្មារតីទទួលខុសត្រូវ និងបុរេសកម្មខ្ពស់របស់រាជរដ្ឋាភិបាល បានបិទបញ្ចប់ **នូវយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជុំទី ១ ជូនដល់ប្រជាជន អាយុចាប់ពី ៥ ឆ្នាំឡើងទៅ ក្នុងក្របខណ្ឌទូទាំងប្រទេស** ដោយបង្កើតបាននូវភាពស៊ាំសហគមន៍រឹងមាំមួយសម្រាប់កម្ពុជា ។ ការណ៍នេះ, បូករួមទាំងការពង្រឹង និងពង្រីកជាបន្តបន្ទាប់នូវសមត្ថភាពប្រព័ន្ធសុខាភិបាល និងការចូលរួមយ៉ាងសស្រាក់សស្រាំពីគ្រប់មជ្ឈដ្ឋាន, អនុញ្ញាតឱ្យកម្ពុជាអាចបើកប្រទេសលើគ្រប់វិស័យឡើងវិញ ។

ក្នុងន័យនេះ, ការរៀបចំ **យុទ្ធសាស្ត្រស្តីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩** នេះ គឺជាកិច្ចការចាំបាច់ និងចំពេល ដែលនឹងជួយសម្រួលដល់ការរៀនរស់នៅជាមួយជំងឺកូវីដ-១៩ ប្រកបដោយសុវត្ថិភាព និងនិរន្តរភាព ។ យុទ្ធសាស្ត្រនេះ នឹងចូលរួមចំណែកដល់ការធានាសុវត្ថិភាពសុខភាពសាធារណៈ, រក្សានិរន្តរភាពនៃសកម្មភាពសង្គម-សេដ្ឋកិច្ច និងត្រួសត្រាយផ្លូវ សម្រាប់ការរៀនរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩ ដែលអាចនឹងផ្តល់ឱកាសឱ្យកម្ពុជាប្រែក្លាយវិបត្តិទៅជាកាលានុវត្តភាព ដូចពាក្យដំណាលបានលើកឡើងថា **«គ្រប់វិបត្តិដែលកើតមានឡើង តែងបង្កប់នូវកាលានុវត្តភាពមាស ដែលយើងមិនគួរមើលរំលង»** ។ ការដាក់ចេញនូវយុទ្ធសាស្ត្រនេះ ក៏នឹងក្លាយទៅជាឧបករណ៍ដ៏ចាំបាច់ ក្នុងការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចជាតិឡើងវិញ ដែលនឹងជួយជំរុញឱ្យសកម្មភាពធុរកិច្ច, ពាណិជ្ជកម្ម និងវិនិយោគ អាចបន្សាំបានលឿន តាមគន្លងប្រក្រតីភាពថ្មី និងចាប់យកកាលានុវត្តភាពថ្មីៗ ជាមួយនឹងផែនការប្រកបដោយភាពច្នៃប្រឌិត, រស់រវើក និងបត់បែនបាន ។ម្យ៉ាងវិញទៀត, យុទ្ធសាស្ត្រនេះ នឹងផ្តល់ទំនុកចិត្តដល់វិនិយោគិន ដែលអាចបង្កើតជាកាលានុវត្តភាពឱ្យកម្ពុជាចាប់យកការប្រែប្រួលនៃនិន្នាការសកល ជាពិសេសការផ្លាស់ប្តូរ និងការធ្វើពិពិធកម្មនៃខ្សែច្រវាក់ផលិតកម្មសកល ។

# បរិសិដ្ឋ

## បរិសិដ្ឋទី១. សាវតារនៃការប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅកម្ពុជា

### ដំណាក់កាលទី ១៖ ការប្រយុទ្ធ និង ការទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ (ចាប់ពីខែ មីនា ឆ្នាំ ២០២០ រហូតដល់ដំណាច់ខែ តុលា ឆ្នាំ ២០២០)

- <u>នៅក្នុងខែ មីនា ឆ្នាំ ២០២០</u> : នៅពេលដែលមានការចាប់ផ្តើមផ្ទុះឡើងនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅជុំវិញសកលលោក ហើយបណ្តាប្រទេសនៅលើសាកលលោកក៏ពុំទាន់យល់ច្បាស់អំពីជំងឺកូវីដ-១៩ និង អំពីវិធីព្យាបាល, មិនទាន់មានវ៉ាក់សាំងបង្ការ និង ឱសថព្យាបាលជំងឺនេះ, ព្រមទាំងមានការខ្វះខាតសម្ភារៈការពារផ្សេងៗ ដូចជា ម៉ាស និង អាល់កុល ជាដើម, **រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រមួយចំនួន ដោយផ្តោតលើ៖**
  - **ការរឹតបន្តឹងនៅតាមច្រកទ្វារព្រំដែន** ដូចជា ការបិទជើងហោះហើរពីបណ្តាប្រទេសមួយចំនួនដែលមានហានិភ័យខ្ពស់នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩, ការបិទច្រកទ្វារចេញ-ចូលប្រទេសជាមួយប្រទេសជិតខាង និង ការតម្រូវឱ្យអ្នកដំណើរមកកម្ពុជាធ្វើចត្តាឡីស័ក និងធ្វើតេស្តរកជំងឺកូវីដ-១៩ ជាដើម សំដៅកាត់បន្ថយការនាំចូលករណីវិជ្ជមានកូវីដ-១៩ ព្រមទាំងបង្ការ និងទប់ស្កាត់ការចម្លងចូលក្នុងសហគមន៍កម្ពុជា និង
  - **ការទប់ស្កាត់មិនឱ្យឆ្លងនៅក្នុងសហគមន៍ផ្ទៃក្នុងប្រទេស** តាមរយៈការរុករក, ការធ្វើតេស្ត, ការធ្វើចត្តាឡីស័កអ្នកពាក់ព័ន្ធផ្ទាល់ និង ប្រយោល, ការបិទទីតាំងប៉ះពាល់ផ្ទាល់ និង ការ-ពង្រឹងសមត្ថភាពព្យាបាល ។
- ជាលទ្ធផល, ការដាក់ចេញនូវវិធានការតឹងរ៉ឹង ក្នុងការទប់ស្កាត់មិនឱ្យមានការនាំចូលនូវមេរោគកូវីដ-១៩ ពីបរទេស បានជួយបញ្ចៀសនូវការឆ្លងរាលដាលក្នុងសហគមន៍នៃជំងឺកូវីដ-១៩ បានរយៈពេលជិត ១ ឆ្នាំ និង បានធ្វើឱ្យកម្ពុជាទទួលបានកេរ្តិ៍ឈ្មោះល្អលើការប្រយុទ្ធ និងការ-ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺនេះ ចូលក្នុងសហគមន៍ នៅក្នុងដំណាក់កាល ទី១ ។ ស្រប ពេលជាមួយគ្នានេះ, ជាទូទៅ កម្ពុជាក៏អាចធានា និងរក្សាបាននូវកិច្ចដំណើរការជាប្រក្រតីនៃសកម្មភាពសង្គម-សេដ្ឋកិច្ច លើកលែងតែវិស័យទេសចរណ៍ និងការធ្វើដំណើរជាអន្តរជាតិ ។

### ដំណាក់កាលទី ២៖ ការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចូលក្នុង សហគមន៍ (ចាប់ពីខែ វិច្ឆិកា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២១)

- <u>**ព្រឹត្តិការណ៍សហគមន៍ ៣ វិច្ឆិកា ២០២០**</u>: កម្ពុជាបានជួបប្រទះនូវការចម្លងជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ជាលើកដំបូង នៅថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែលបានបង្កឱ្យមានភាពរអាក់រអួលដល់ដំណើរការងាររបស់រាជរដ្ឋាភិបាល ដោយថ្នាក់ដឹកនាំ និងមន្ត្រីរាជការមួយចំនួនត្រូវធ្វើចត្តាឡីស័ក ក្រោយពីមានការទាក់ទងដោយផ្ទាល់ និងដោយប្រយោល ជាមួយគណៈប្រតិភូជាន់ខ្ពស់នៃក្រសួងការបរទេសហុងគ្រី ។

- **ព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា ២០២០** : កម្ពុជាបានជួបប្រទះនូវការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍, ជា "**រលកទី១**", ដែលបានកើតចេញពីប្រភពផ្សេងមួយទៀត និង បានប៉ះពាល់ដល់ប្រជាជនទូទៅ ជាពិសេស នៅរាជធានីភ្នំពេញ និង ខេត្តសៀមរាប ។
- ដើម្បីឆ្លើយតប និងគ្រប់គ្រងព្រឹត្តិការណ៍សហគមន៍ទាំង ២ លើកនេះ, រាជរដ្ឋាភិបាលបានជំរុញការអនុវត្តវិធានការ **៣-ធី (3-Ts)** ពោលគឺ ការធ្វើតេស្ត (Testing), ការរុករក (Tracking) និង ការព្យាបាល (Treatment) គួបផ្សំជាមួយនឹងការរឹតត្បិតលើការធ្វើដំណើរ, ការបិទទីតាំងដែលមានអ្នកជំងឺកូវីដ-១៩ ចូល និងការតម្រូវឱ្យអ្នកប៉ះពាល់ជាមួយអ្នកជំងឺកូវីដ-១៩ ទាំងអស់ ធ្វើចត្តាឡីស័ក ។
- **នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០** : តាមរយៈការឆ្លើយតប, ការដាក់ចេញនូវវិធានការតឹងរ៉ឹង និងការចូលរួមពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ក្រោមស្មារតីប្រុងប្រយ័ត្នខ្ពស់, "**រលកទី១**" នេះ ត្រូវបានបិទបញ្ចប់ទៅវិញត្រឹមរយៈពេល ១ ខែ ជាមួយនឹងការរកឃើញអ្នកវិជ្ជមានកូវីដ-១៩ ចំនួន ៤១ នាក់ និង ពុំមានអ្នកបាត់បង់អាយុជីវិតដោយសារជំងឺកូវីដ-១៩ ឡើយ ។
- **នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០២១** : កម្ពុជាបានទទួលវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ប្រភេទស៊ីណូហ្វាម (Sinopharm) ជាលើកដំបូងបំផុត ចំនួន ៦០ ម៉ឺនដូស ដែលជាជំនួយរបស់រដ្ឋាភិបាលចិន ។
- **នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២១** : រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចិត្តយ៉ាងត្រឹមត្រូវ និងទាន់ពេល ក្នុងការបើក **យុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជំហានទី ១** ជូនដល់អ្នកបម្រើសេវាជួរមុខ ក្នុងក្របខណ្ឌទូទាំងប្រទេស (ដូចជា បុគ្គលិកសុខាភិបាល, កងកម្លាំងប្រដាប់អាវុធ និង មន្ត្រីសាធារណៈ) ។

## ដំណាក់កាលទី ៣៖ ការបង្កើត "ភាពស៊ាំក្នុងសហគមន៍" ប្រឆាំងនឹងជំងឺកូវីដ-១៩ តាមរយៈការអនុវត្តយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ គួបផ្សំជាមួយនឹងការបន្តគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ (ចាប់ពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២១ រហូតដល់ដំណាច់ខែ តុលា ឆ្នាំ ២០២១)

- **ខណៈដែលការចាក់វ៉ាក់សាំងត្រូវបានចាប់ផ្តើម, ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១** បានបង្កើតឡើងនូវការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ក្នុងទ្រង់ទ្រាយធំ ជាលើកដំបូង ដែលត្រូវបានចាត់ទុកជា "**រលកទី២**" ។ ការឆ្លងរាលដាលទ្រង់ទ្រាយធំក្នុងព្រឹត្តិការណ៍នេះ បានធ្វើឱ្យកម្ពុជាជួបបញ្ហាប្រឈមធ្ងន់ធ្ងរ, ទាំងផ្នែកសុខភាពសាធារណៈ, ទាំងផ្នែកសង្គម-សេដ្ឋកិច្ច, ដែលបានធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន, សកម្មភាពអាជីវកម្ម, ពាណិជ្ជកម្ម និង សេដ្ឋកិច្ច ។ "**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ឆ្នាំ២០២១**" នេះ បានធ្វើឱ្យកម្ពុជាមានអ្នកឆ្លងជំងឺកូវីដ-១៩ កើនឡើងច្រើនយ៉ាងគំហុក ហើយធ្វើឱ្យជំងឺនេះឆ្លងរាលដាលនៅទូទាំងប្រទេស ព្រមទាំងមានអ្នកបាត់បង់អាយុជីវិតដោយសារជំងឺនេះកើតឡើង ជារៀងរាល់ថ្ងៃ ។

- **<u>នៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២១</u>** : នៅពេលដែលការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ កំពុងមានសភាពខ្លាំងក្លា និងក្នុងទិសដៅកាត់បន្ថយផលវិបាក ព្រមទាំងជួយសង្គ្រោះអាយុជីវិតប្រជាជន, រាជរដ្ឋាភិបាលក៏បានប្រកាសឱ្យប្រើប្រាស់ **ច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និង ប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត** ដែលក្នុងនោះមាន ការដាក់ទណ្ឌកម្ម និងពិន័យ ដើម្បីជំរុញឱ្យប្រជាពលរដ្ឋ និង គ្រប់ភាគីពាក់ព័ន្ធអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការសុខាភិបាល សំដៅការពារសុវត្ថិភាពរបស់សហគមន៍នៅក្នុងទូទាំងប្រទេស ។
- **<u>នៅថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០២១</u>** : ដោយសារសម្ទុះដ៏លឿននៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងក្នុងគោលបំណងការពារអាយុជីវិតប្រជាជន, រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវ **វិធានការបិទខ្ទប់ក្នុងទ្រង់ទ្រាយធំ ជាលើកទី ១ សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ និង ក្រុងតាខ្មៅនៃខេត្តកណ្ដាល រយៈពេល ២១ ថ្ងៃ** (ចាប់ពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០២១ រហូតដល់ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០២១) ព្រមទាំង**ការបិទចរាចរណ៍មនុស្សឆ្លងកាត់ព្រំប្រទល់រាជធានី-ខេត្ត រយៈពេល ១៨ ថ្ងៃ** ។ ជារួម, វិធានការទាំងនេះ បានជួយទប់ស្កាត់មិនឱ្យកម្ពុជាធ្លាក់ចូលក្នុង **"ជ្រោះមរណៈ"** ដោយបានរារាំងដល់ការចល័តមនុស្សរាប់លាននាក់ នៅទូទាំងប្រទេស ក្នុងឱកាសនៃការឈប់សម្រាកបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ព្រមទាំងបានជួយកាត់ផ្ដាច់ និង កាត់បន្ថយការឆ្លងរាលដាលនៃជំងឺនេះ បានមួយកម្រិតធំ ។
- **<u>នៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១</u>** : ដោយសង្កេតឃើញថា ករណីឆ្លងរាលដាលមានលក្ខណៈជាចង្កោម, រាជរដ្ឋាភិបាលបានសម្រេចបន្ធូរបន្ថយវិធានការបិទខ្ទប់ ដោយកំណត់ភូមិសាស្ត្ររាជធានីភ្នំពេញជា ៣ តំបន់ គឺ តំបន់ក្រហម, តំបន់លឿងទុំ និង តំបន់លឿង ទៅតាមកម្រិតនៃហានិភ័យជាក់ស្ដែង ។
- **<u>នៅថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០២១</u>** : បន្ទាប់ពីធានាបាននូវបរិមាណវ៉ាក់សាំងសមរម្យ, រាជរដ្ឋាភិបាល ក៏បានដាក់ចេញនូវ **ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតឱ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ក្នុងឆ្នាំ ២០២១** ។ ការប្រើប្រាស់អភិក្រម «**ផ្ការរីក**» ដោយប្រមូលផ្ដុំកម្លាំងសរុបរបស់ជាតិមកចូលរួមក្នុងការអនុវត្ត និង ចាប់ផ្ដើមពីចំណុចកណ្ដាលនៃប្រទេស ពោលគឺ ផ្ដើមចេញពីរាជធានីភ្នំពេញ និង តំបន់ទីប្រជុំជនសំខាន់ៗជុំវិញរាជធានីភ្នំពេញ ហើយពង្រីកជាជំហានៗទៅកាន់តំបន់ផ្សេងទៀត ស្របតាមលំដាប់លំដោយនៃការធ្វើអាទិភាវូបនីយកម្ម ។
- **<u>នៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០២១</u>** : បន្ទាប់ពីបានធ្វើការកែសម្រួលពង្រឹងយន្តការស្ថាប័នប្រយុទ្ធនឹងជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលបានប្រកាសដាក់ចេញនូវវិធានការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ពិសេស **យុទ្ធសាស្ត្រចំនួន ៦ ចំណុច** របស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី ដើម្បីប្រយុទ្ធ និង ទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩** ដូចខាងក្រោម៖
  - **យុទ្ធសាស្ត្រទី ១ :** បន្តទប់ស្កាត់ការនាំចូលមេរោគកូវីដ-១៩ បំប្លែងថ្មី,
  - **យុទ្ធសាស្ត្រទី ២ :** កាត់បន្ថយទំហំតំបន់ឆ្លង និង ចំនួនឆ្លងឱ្យនៅកម្រិតទាបបំផុត,

- **យុទ្ធសាស្ត្រទី ៣** : បន្តខិតខំព្យាបាលអ្នកឆ្លងជំងឺកូវីដ-១៩ ឱ្យបានជាសះស្បើយ និង កាត់បន្ថយអត្រាអ្នកបាត់បង់អាយុជីវិតដោយសារជំងឺកូវីដ-១៩ និង ឈានទៅគ្មានអ្នកបាត់បង់អាយុជីវិត,
- **យុទ្ធសាស្ត្រទី ៤** : រុករក និង គ្រប់គ្រងករណីពាក់ព័ន្ធជំងឺកូវីដ-១៩,
- **យុទ្ធសាស្ត្រទី ៥** : រៀបចំបូជា និង បញ្ចុះសពអ្នកជំងឺកូវីដ-១៩ ឱ្យបានល្អប្រសើរ និង
- **យុទ្ធសាស្ត្រទី ៦** : ជំរុញយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ។

- **<u>នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០២១</u>** : រាជរដ្ឋាភិបាល បាន បើកយុទ្ធនាការទ្រង់ទ្រាយធំ ក្នុងការរុករកអ្នកពាក់ព័ន្ធនឹងអ្នកវិជ្ជមានកូវីដ-១៩ ដោយប្រើប្រាស់ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនមេរោគកូវីដ-១៩ តាមអភិក្រម "**រកឃើញឆាប់រហ័ស, គ្រប់គ្រងបានលឿន និងកាត់ផ្តាច់ខ្សែច្រវាក់ការឆ្លងរាលដាលបានទាន់ពេល**" ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលក៏បានបើកទូលាយឱ្យស្ថាប័នរដ្ឋ, វិស័យឯកជន ក៏ដូចជាប្រជាពលរដ្ឋទូទៅ អាចប្រើប្រាស់ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនមេរោគកូវីដ-១៩ ។
- **<u>នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២១</u>** : រាជរដ្ឋាភិបាល បានប្រកាសដាក់ចេញនូវ **វិធានការបិទខ្ទប់បណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ និង ខេត្តសៀមរាប រយៈពេល ១៤ ថ្ងៃ** (ចាប់ពីថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០២១ ដល់ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០២១) និង ការដាក់ចេញនូវ "**យុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩**" នៅទូទាំងប្រទេស ដើម្បីប្រយុទ្ធ, ទប់ស្កាត់ និង គ្រប់គ្រងការឆ្លងរាលដាលទ្រង់ទ្រាយធំនៃជំងឺកូវីដ-១៩ ដែលបណ្តាលមកពីមេរោគបំប្លែងខ្លួនថ្មី ប្រភេទ Delta ដែលត្រូវបានរកឃើញដំបូងនៅកម្ពុជា កាលពីចុងខែ មិថុនា ឆ្នាំ ២០២១ នៅខេត្តឧត្តរមានជ័យ និង មានកម្រិតនៃការឆ្លងរាលដាលលឿន ។
- **<u>នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០២១</u>** : រាជរដ្ឋាភិបាលបានពង្រីកវិសាលភាពនៃយុទ្ធនាការជាតិចាក់វ៉ាក់សាំង ជូនដល់ **កុមារ-យុវវ័យ អាយុចាប់ពី ១២ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ** ។
- **<u>នៅថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០២១</u>** : រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវយុទ្ធនាការ **អប់រំ, ផ្សព្វផ្សាយ និងបណ្តុះបណ្តាលប្រជាពលរដ្ឋ** ក្រោមប្រធានបទ "**រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងមេរោគកូវីដ-១៩**" ។
- **<u>នៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០២១</u>** : រាជរដ្ឋាភិបាល បានសម្រេចដាក់ចេញនូវយន្តការពង្រឹងសមត្ថភាពក្នុងការព្យាបាលអ្នកជំងឺកូវីដ-១៩ ដើម្បីកាត់បន្ថយចំនួនអ្នកស្លាប់ និង ឈានទៅគ្មានអ្នកបាត់បង់អាយុជីវិតដោយសារជំងឺកូវីដ-១៩ តាមរយៈការពង្រីកសេវាសង្គ្រោះបន្ទាន់ និង ICU នៅតាមមន្ទីរពេទ្យនៃរាជធានី-ខេត្ត និង ការបង្កើតមន្ទីរពេទ្យផ្តល់សេវា ICU ថ្នាក់តំបន់ រួមទាំងការធានាបាននូវការផ្គត់ផ្គង់អុកស៊ីហ្សែន និងថ្នាំព្យាបាល ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលក៏បានបើកទូលាយឱ្យមានការចូលរួមពីសេវាសុខាភិបាលឯកជន ក្នុងការព្យាបាលជំងឺកូវីដ-១៩ និង បានពង្រឹងសមត្ថភាពក្នុងការព្យាបាលអ្នកជំងឺកូវីដ-១៩ កម្រិតស្រាល នៅតាមផ្ទះ ។
- **<u>នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០២១</u>** : រាជរដ្ឋាភិបាលបានបើកយុទ្ធនាការជាតិចាក់វ៉ាក់សាំងជូនដល់ **កុមារអាយុពី ៦ ឆ្នាំ ដល់ក្រោម ១២ ឆ្នាំ** និង បើក **យុទ្ធនាការជាតិចាក់វ៉ាក់សាំងដូសជំរុញ**

ជូនដល់ប្រជាពលរដ្ឋទូទៅ ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ សំដៅសម្រេចឱ្យបាននូវភាពស៊ាំសហគមន៍ពេញលេញ និង រឹងមាំ នៅទូទាំងកម្ពុជា ។

## ដំណាក់កាលទី ៤៖ ការបើកដំណើរការប្រទេសពេញលេញឡើងវិញ លើគ្រប់វិស័យ និង ការរស់នៅជាមួយជំងឺកូវីដ-១៩ "តាមគន្លងប្រក្រតីភាពថ្មី" (ចាប់ពីថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០២១ តទៅមុខ)

- **នៅថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០២១ :** រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសបិទជាផ្លូវការនូវយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជុំទី ១ ជូនដល់ប្រជាជន អាយុចាប់ពី ៦ ឆ្នាំឡើងទៅក្នុងក្របខណ្ឌទូទាំងប្រទេស និងបានប្រកាសបើកប្រទេសឡើងវិញលើគ្រប់វិស័យ ជាបណ្តើរៗ សំដៅស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចឡើងវិញតាម «គន្លងប្រក្រតីភាពថ្មី» ។

## បរិសិដ្ឋទី២. សមត្ថភាពនៃប្រព័ន្ធសុខាភិបាល

គិតត្រឹមថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២១៖

- សមត្ថភាពនៃការធ្វើតេស្តបញ្ជាក់វិជ្ជមានមេរោគកូវីដ-១៩ (PCR) ត្រូវបានបង្កើនឡើង ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនមេរោគកូវីដ-១៩ ទូលំទូលាយ នៅក្នុងវិស័យសាធារណៈ និងឯកជន ។
- ចំនួនមន្ទីរពិសោធន៍សម្រាប់បម្រើការធ្វើតេស្តសំណាក មានទីតាំងសរុបចំនួន ១៦ រាជធានី-ខេត្ត និងមានសមត្ថភាពអាចធ្វើតេស្តចន្លោះពី ៧.០០០-៨.០០០ តេស្តក្នុងមួយថ្ងៃ ។ ក្នុងករណីមានការផ្ទុះឆ្លងរាលដាល ក្នុងទ្រង់ទ្រាយធំ មន្ទីរពិសោធន៍ទាំងនេះអាចមានលទ្ធភាពធ្វើតេស្តបានដល់ ១០.០០០-១២.០០០ តេស្តក្នុងមួយថ្ងៃ ដែលនេះមិនទាន់រាប់បញ្ចូលនូវមន្ទីរពិសោធន៍ខ្នាតតូចនៅទូទាំងប្រទេស និងផ្នែកឯកជន ផង ។
  - ✓ មន្ទីរពិសោធន៍នៅរាជធានីភ្នំពេញ មានចំនួន ០៥ ទីតាំង៖ ១. វិទ្យាស្ថានជាតិសុខភាពសាធារណៈ, ២. វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា, ៣. មន្ទីរពិសោធន៍នៃមជ្ឈមណ្ឌលជាតិផ្តល់ឈាម, ៤. មន្ទីរពិសោធន៍នៃមន្ទីរពេទ្យព្រះកេតុមាលា និង ៥. មន្ទីរពិសោធន៍នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ។
  - ✓ មន្ទីរពិសោធន៍នៅតាមបណ្តាខេត្ត មានចំនួន ០២ ទីតាំង៖ ១. ខេត្តប៉ៃលិន និង ២. ខេត្តពោធិ៍សាត់ ។
- បណ្តាញមណ្ឌលចត្តាឡីស័កត្រូវបានពង្រីកនៅតាមរាជធានី-ខេត្ត ជាពិសេស នៅតាមបណ្តាខេត្តនៅជាប់ព្រំដែនភាគខាងលិច រួមជាមួយនឹងការពង្រីកទីតាំងចត្តាឡីស័កក្នុងវិស័យឯក-ជន (ដូចជានៅតាមសណ្ឋាគារជាដើម) និងបណ្តាញនៃការធ្វើចត្តាឡីស័កតាមលំនៅឋាន ។
- មន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ មានចំនួន ៧៩ កន្លែង និងមណ្ឌលព្យាបាលជំងឺកូវីដ-១៩ មានចំនួន ១៤៥ កន្លែង ក្នុងនោះ៖
  - ✓ គ្រែកម្រិតស្រាល ៤៣.៧៦៤ គ្រែ (នៅមន្ទីរពេទ្យ/មណ្ឌលព្យាបាលមិនមែនជាសាលារៀន មានចំនួន ២៧.៧៩៤ គ្រែ និងជាសាលារៀន មានចំនួន ១.៥៩៧០ គ្រែ) និងគ្រែដែលត្រូវបានត្រៀមបំរុងទុកចំនួន ១៣.១៧៩ គ្រែ ។
  - ✓ គ្រែសង្គ្រោះបន្ទាន់កម្រិតធ្ងន់ ICU មាន ចំនួនសរុប ១.៦២៦គ្រែ នៅមន្ទីរពេទ្យ/មណ្ឌលព្យាបាលរដ្ឋ និងគ្រែដែលត្រូវបានត្រៀមបំរុងទុកមានចំនួន ៧០២ គ្រែ ។
  - ✓ គ្រែទំនេរនៅសល់សរុប ៥២,៩៦% ក្នុងនោះ គ្រែធម្មតានៅសល់ ៥២,៩២% និង គ្រែ ICU នៅសល់ ៥៤,៥០% ។
- ត្រៀមបំរុងសម្ភារៈ-បរិក្ខារចាំបាច់នានា សម្រាប់ករណីមានការផ្ទុះឆ្លងរាលដាល ក្នុងទ្រង់ទ្រាយធំ ដូចជា ម៉ាស៊ីនផលិតអុកស៊ីហ្សែន, ឧបករណ៍តេស្ត, ឱសថ, ឧបករណ៍ការពារខ្លួន (PPE) ជាដើម ។
- គ្រូពេទ្យ-បុគ្គលិកបំរើការងារ នៅមន្ទីរពេទ្យ និងមណ្ឌលព្យាបាល មានចំនួន ២១.០១៩ នាក់ ក្នុងនោះរួមមាន៖ វេជ្ជបណ្ឌិតឯកទេស/វេជ្ជបណ្ឌិត ១.៤៨៦ នាក់, គិលានុបដ្ឋាក/ឆ្មប និង

បុគ្គលិកជំនាញសុខាភិបាលផ្សេងទៀត ៤.៥៧៧ នាក់  មន្ត្រី-បុគ្គលិកសុខាភិបាលដទៃទៀត ៦.០៦៣នាក់ ។ គ្រូពេទ្យ-បុគ្គលិក ប្រមាណ ៣.០០០នាក់ បានត្រៀមបំរុងទុកសម្រាប់ករណីមានការផ្ទុះឆ្លងរាលដាល ក្នុងទ្រង់ទ្រាយធំ ។

## បរិសិដ្ឋទី៣. ភាពស៊ាំសហគមន៍ប្រឆាំងនឹងមេរោគកូវីដ-១៩

ភាពស៊ាំសហគមន៍ (Herd immunity or population immunity) ការពារប្រជាជនពីជំងឺឆ្លងណាមួយដែលបានកើតឡើង ។ តាមទ្រឹស្តីផ្នែកភាពស៊ាំ, កម្រិតគ្រប់គ្រាន់នៃភាពស៊ាំសហគមន៍ធ្វើឱ្យមេរោគដែលបង្កជំងឺលែងសកម្មក្នុងការចម្លង និងអាចការពារដោយប្រយោលដល់ប្រជាជនទាំងអស់ ដោយរាប់បញ្ចូលទាំងប្រជាជនដែលគ្មានភាពស៊ាំក្នុងខ្លួន ។ ភាពស៊ាំសហគមន៍អាចនឹងសម្រេចបានតាមរយៈ (១) ការចាក់វ៉ាក់សាំង ឬ (២) ការបណ្តោយឱ្យជំងឺឆ្លងរាលដាលក្នុងចំណោមប្រជាជន ។ មធ្យោបាយទីពីរនេះ ធ្វើឱ្យប្រជាជនយ៉ាងច្រើនសន្ធឹកសន្ធាប់ឆ្លងជំងឺ និងបាត់បង់អាយុជីវិត ។

ភាគរយនៃប្រជាជនដែលត្រូវមានភាពស៊ាំក្នុងខ្លួន ដើម្បីសម្រេចបានភាពស៊ាំសហគមន៍ ប្រែប្រួលទៅតាមប្រភេទជំងឺឆ្លងនីមួយៗ ។ រហូតមកដល់ពេលនេះ, សកលលោកមិនទាន់មានយល់ឃើញដូចគ្នាពីកម្រិតគ្រប់គ្រាន់នៃភាពស៊ាំសហគមន៍ប្រឆាំងនឹងមេរោគកូវីដ-១៩ នៅឡើយ ។ ការសិក្សាស្រាវជ្រាវខ្លះបានប៉ាន់ស្មានថា នៅដំណាក់កាលដំបូងនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩, កម្រិតគ្រប់គ្រាន់នៃភាពស៊ាំសហ-គមន៍ប្រឆាំងមេរោគកូវីដ-១៩ ត្រូវការពី ៦០-៧០% នៃប្រជាជនសរុបត្រូវមានភាពស៊ាំក្នុងខ្លួន ។ ប៉ុន្តែ, នៅពេលលេចឡើងនូវមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មី, ក្រុមអ្នកជំនាញផ្នែកអេពីដេមីសាស្ត្រមួយចំនួនជឿថា កម្រិតគ្រប់គ្រាន់នៃភាពស៊ាំសហគមន៍គប្បីមានអត្រា ៧៥-៩០% ។ អង្គការសុខភាពពិភពលោកបានផ្តល់អនុសាសន៍ថា ជាការល្អបំផុតត្រូវចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឱ្យបានលើសពី ៩០% នៃចំនួនប្រជា-ជន ដើម្បីទប់ទល់ជាមួយមេរោគកូវីដ-១៩ បំលែងខ្លួនថ្មី ។ ជាមួយគ្នានេះ, អង្គការ GAVI (Global Alliance for Vaccination and Immunization) បានលើកឡើងថា ដើម្បីឱ្យសកលលោកមានសុវត្ថិភាពមនុស្សគ្រប់រូបត្រូវចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដោយរាប់បញ្ចូលទាំងកុមារផងដែរ ។

ការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រជាច្រើនអំពីប្រសិទ្ធភាពនៃវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ បានបញ្ជាក់អះអាងថា ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដែលមានសុវត្ថិភាព និងប្រសិទ្ធភាព ជួយបង្ការការចម្លង និងកាត់បន្ថយការឈឺធ្ងន់ធ្ងរ និងការបាត់បង់អាយុជីវិត ។ គួរគូសបញ្ជាក់ថា កម្រិតភាពស៊ាំដែលទទួលបានពីការវ៉ាក់សាំង បានថយចុះជាបន្តបន្ទាប់ទៅតាមពេលវេលា ។ តាមរយៈការសិក្សាស្រាវជ្រាវឯក-សារ, ក្រុមការងារជំនាញនៃក្រសួងសុខាភិបាល បានសន្និដ្ឋានកម្រិតភាពស៊ាំប្រឆាំងនឹងមេរោគកូវីដ-១៩ អាចស្ថិតនៅរយៈពេលប្រមាណពី ៦-៨ ខែ ក្រោយពេលបានចាក់វ៉ាក់សាំងគ្រប់ដូស ហើយមេរោគបំប្លែងខ្លួនថ្មី ដូចជាប្រភេទដែលតា ជាដើម មានសមត្ថភាពបន្ថយប្រសិទ្ធភាពវ៉ាក់សាំង ។ ក្នុងន័យនេះ, ការចាក់វ៉ាក់សាំងដូសជំរុញ គឺជាវិធានការដ៏សមស្របដើម្បីរក្សាភាពស៊ាំសហគមន៍ឱ្យនៅរឹងមាំជាប្រចាំ ។

## បរិសិដ្ឋទី៤. ការវាយតម្លៃកម្រិតហានិភ័យលើសុខភាពសាធារណៈនៃជំងឺកូវីដ-១៩

ក្រសួងសុខាភិបាល និងរដ្ឋបាលរាជធានី-ខេត្ត ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវតាមដាន និងវាយតម្លៃកម្រិតហានិភ័យសុខភាពសាធារណៈ និងសមត្ថភាពប្រព័ន្ធសុខាភិបាល ជាប្រចាំ (ជារៀងរាល់ថ្ងៃ និងរៀងរាល់សប្តាហ៍) ដើម្បីកំណត់កម្រិតហានិភ័យសុខភាពសាធារណៈ ដោយប្រើប្រាស់ កូដពណ៌ ផ្សេងៗ ។ កម្រិតហានិភ័យសុខភាពសាធារណៈ ត្រូវបានវាយតម្លៃ ដោយប្រើប្រាស់ សូចនាករសុខភាពសាធារណៈ ចំនួន ២ (ពីរ) ដើម្បីធ្វើការសន្និដ្ឋានពីស្ថានភាពនៃការឆ្លងរាលដាល រួមជាមួយនឹងសូចនាករសមត្ថភាពប្រព័ន្ធសុខាភិបាលចំនួន ១ (មួយ) ដូចមានបង្ហាញនៅក្នុងតារាងទី១ ខាងក្រោម ។ តម្លៃគោល (thresholds) នៃសូចនាករសុខភាពសាធារណៈ ត្រូវបានកំណត់ឡើង ដោយផ្អែកលើមូលដ្ឋាននៃការ-ចាក់វ៉ាក់សាំងដែលអាចជួយកាត់បន្ថយការឈឺធ្ងន់ធ្ងរ និងឈានដល់ការសម្រាកពេទ្យ និងការបាត់បង់អាយុជីវិត ។ ក្រសួងសុខាភិបាល នឹងពិនិត្យ និងធ្វើបច្ចុប្បន្នភាពនៃសូចនាករ និងតម្លៃគោលនៃសូចនាករទាំងនេះ យោងតាមស្ថានភាពវិវត្តជាក់ស្តែងនៃការគ្រប់គ្រងជំងឺកូវីដ-១៩។

### តារាងទី១. ការសន្និដ្ឋានពីស្ថានភាពនៃការចម្លងជំងឺកូវីដ-១៩

| | កម្រិតស្ថានភាពនៃការចម្លង | | | |
|---|---|---|---|---|
| **សូចនាករ** | ទាប | មធ្យម | ខ្ពស់ | ខ្ពស់ខ្លាំង |
| **១.** អត្រាអ្នកជំងឺកូវីដ-១៩ ថ្មី សម្រាកព្យាបាល (រាប់បញ្ចូលទាំងអ្នកជំងឺ ICU) ក្នុងចំណោមប្រជាជន ១០០.០០០នាក់ ក្នុង ១សប្តាហ៍ គិតជាមធ្យមភាគក្នុងរយៈពេល ២ សប្តាហ៍ កន្លងមក | < ៥ | ៥ - < ១០ | ១០- <៣០ | ៣០+ |
| **២.** អត្រាស្លាប់នៃអ្នកជំងឺកូវីដ-១៩ សម្រាកព្យាបាល ក្នុង ១ សប្តាហ៍ ក្នុងចំណោមប្រជាជន ១០០.០០០នាក់ គិតជាមធ្យមភាគក្នុងរយៈពេល ២ សប្តាហ៍ កន្លងមក | < ១ | ១ - <៣ | ៣ - <៥ | ៥+ |

មន្ទីរពេទ្យ/មណ្ឌលព្យាបាលអ្នកជំងឺកូវីដ-១៩ ទាំងអស់ ត្រូវកត់ត្រាចំនួនអ្នកជំងឺកូវីដ-១៩ ថ្មី ដែលចូលសម្រាកព្យាបាលនៅក្នុងថ្ងៃនីមួយៗ និងកត់ត្រាពីទីកន្លែងដែលអ្នកជំងឺកំពុងរស់នៅ (ទីតាំងភូមិ-សាស្ត្រដែលអ្នកជំងឺស្ថិតនៅ ពេលឆ្លងជំងឺកូវីដ-១៩) ឱ្យបានច្បាស់លាស់ ដើម្បីជាមូលដ្ឋានសម្រាប់ប៉ាន់-ស្មានអំពីស្ថានភាពនៃការចម្លងតាមភូមិសាស្ត្រនៃរាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ។

សូនាករនៃអត្រាប្រើប្រាស់គ្រែ ICU ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងសមត្ថភាពនៃប្រព័ន្ធសុខាភិបាលក្នុងក្របខណ្ឌទូទាំងប្រទេស ឬ រាជធានី-ខេត្ត ឬ ក្រុង-ស្រុក-ខណ្ឌ ដែលមានចំណាត់ថ្នាក់៖ គ្រប់គ្រាន់, មធ្យម និងមានកម្រិត ដូចបានបញ្ជាក់ក្នុងតារាង ទី២ ខាងក្រោម ។ **សមត្ថភាពដែលមន្ទីរពេទ្យ/មណ្ឌលព្យាបាលអាចទទួលរ៉ាប់រងព្យាបាល និងថែទាំអ្នកជំងឺកូវីដ-១៩ ដែលត្រូវការសង្គ្រោះ ICU ប្រចាំថ្ងៃ ឬ ហៅថា "បន្ទាត់ក្រហម"** នៃសមត្ថភាពប្រព័ន្ធសុខាភិបាល ។ ការតាមដាននិន្នាការជាប្រចាំ នូវអត្រាការប្រើ-ប្រាស់គ្រែ ICU នៃអ្នកជំងឺកូវីដ-១៩ ក្នុងរយៈពេល ១ សប្តាហ៍, ២ សប្តាហ៍ និងក្នុងរយៈពេល ២៨ ថ្ងៃ អាចជួយ

ឱ្យធ្វើការសន្និដ្ឋានបាន អំពីស្ថានភាពនៃឆ្លងរាលដាលនៅក្នុងសហគមន៍ និងការសម្រេចដាក់ចេញនូវវិធានការសមស្រប ឬចាំបាច់នានា ដើម្បីគ្រប់គ្រងហានិភ័យឱ្យបានទាន់ពេល និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

### តារាងទី២. ការវាយតម្លៃសមត្ថភាពប្រព័ន្ធសុខាភិបាល

| | កម្រិតសមត្ថភាពនៃប្រព័ន្ធសុខាភិបាល | | |
|---|---|---|---|
| **សូចនាករ** | គ្រប់គ្រាន់ | មធ្យម | មានកម្រិត |
| អត្រាប្រើប្រាស់គ្រែ ICU នៃអ្នកជំងឺកូវីដ-១៩ ប្រចាំថ្ងៃ ក្នុងចំណោមចំនួនគ្រែ ICU សរុប | <២០% | ២០-<៥០% | ៥០% + |

ការវាយតម្លៃហានិភ័យសុខភាពសាធារណៈ ដោយផ្អែកលើការប៉ាន់ស្មានកម្រិតនៃការឆ្លងរាលដាល និងកម្រិតសមត្ថភាពនៃប្រព័ន្ធសុខាភិបាល ត្រូវបានបង្ហាញនៅក្នុងតារាងទី ៣ និង/ឬ តារាងទី ៤ យោងទៅតាមស្ថានភាពជាក់ស្តែង និងភាពងាយស្រួលក្នុងការវាយតម្លៃ ក្នុងក្របខណ្ឌទូទាំងប្រទេស ឬ រាជធានី-ខេត្ត ឬ ក្រុង-ស្រុក-ខណ្ឌ ។

### តារាង ទី៣. ការវាយតម្លៃកម្រិតហានិភ័យសុខភាពសាធារណៈ (១)

(ដោយប្រើប្រាស់សូចនាករ អត្រាអ្នកជំងឺកូវីដ-១៩ ថ្មី សម្រាកព្យាបាល និងអត្រាប្រើប្រាស់គ្រែ ICU)

| | | | សមត្ថភាពនៃប្រព័ន្ធសុខាភិបាល (អត្រាប្រើប្រាស់គ្រែ ICU) | | |
|---|---|---|---|---|---|
| | | | គ្រប់គ្រាន់ (<២០%) | មធ្យម (២០ - <៥០%) | មានកម្រិត (៥០% +) |
| **ស្ថានភាពនៃការចម្លង (អត្រាសម្រាកពេទ្យ)** | កម្រិតចម្លង ទាប | <៥ | ហានិភ័យកម្រិត ១ | ហានិភ័យកម្រិត ២ | ហានិភ័យកម្រិត ២ |
| | កម្រិតចម្លង មធ្យម | ៥ - <១០ | ហានិភ័យកម្រិត ២ | ហានិភ័យកម្រិត ២ | ហានិភ័យកម្រិត ៣ |
| | កម្រិតចម្លង ខ្ពស់ | ១០ - <៣០ | ហានិភ័យកម្រិត ២ | ហានិភ័យកម្រិត ៣ | ហានិភ័យកម្រិត ៣ |
| | កម្រិតចម្លង ខ្ពស់ខ្លាំង | ៣០+ | ហានិភ័យកម្រិត ៣ | ហានិភ័យកម្រិត ៣ | ហានិភ័យកម្រិត ៤ |

### តារាង ទី៤. ការវាយតម្លៃកម្រិតហានិភ័យសុខភាពសាធារណៈ (២)

(ដោយប្រើប្រាស់សូចនាករ អត្រាស្លាប់នៃអ្នកជំងឺកូវីដ-១៩ សម្រាកព្យាបាល និងអត្រាប្រើប្រាស់គ្រែ ICU)

| | | | សមត្ថភាពប្រព័ន្ធសុខាភិបាល (អត្រាប្រើប្រាស់គ្រែ ICU) | | |
|---|---|---|---|---|---|
| | | | គ្រប់គ្រាន់ (<២០%) | មធ្យម (២០ - <៥០%) | មានកម្រិត (៥០% +) |
| **ស្ថានភាពនៃការចម្លង (អត្រាស្លាប់)** | កម្រិតចម្លង ទាប | < ១ | ហានិភ័យកម្រិត ១ | ហានិភ័យកម្រិត ២ | ហានិភ័យកម្រិត ២ |
| | កម្រិតចម្លង មធ្យម | ១ - <៣ | ហានិភ័យកម្រិត ២ | ហានិភ័យកម្រិត ២ | ហានិភ័យកម្រិត ៣ |
| | កម្រិតចម្លង ខ្ពស់ | ៣ - <៥ | ហានិភ័យកម្រិត ២ | ហានិភ័យកម្រិត ៣ | ហានិភ័យកម្រិត ៣ |
| | កម្រិតចម្លង ខ្ពស់ខ្លាំង | ៥+ | ហានិភ័យកម្រិត ៣ | ហានិភ័យកម្រិត ៣ | ហានិភ័យកម្រិត ៤ |

ការកំណត់បានពីកម្រិតហានិភ័យសុខភាពសាធារណៈ គឺជាវិចារណកម្មដ៏រឹងមាំ គាំទ្រដល់ការ-សម្រេចដាក់ចេញនូវវិធានការសមស្រប ឬចាំបាច់នានា ឬការត្រៀមលក្ខណៈទុកជាមុន ដើម្បីគ្រប់គ្រងហានិភ័យសុខភាពសាធារណៈ ឱ្យបានទាន់ពេល យោងតាមទស្សនាទាន ដូចខាងក្រោមៈ

- **កម្រិត ទី១ (ទាបៈ ប្រុងប្រយ័ត្នជាធម្មតា)**៖ ស្ថានភាពនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ មានកម្រិតទាប (មានជាករណី ឬ ជាចង្កោមខ្លះ) ឬស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុង និងប្រព័ន្ធ សុខាភិបាលមានសមត្ថភាពគ្រប់គ្រាន់ ។ បន្តការអនុវត្តវិធានការសុខាភិបាលជាមូលដ្ឋាន "៣ ការពារ ៣ កុំ" ដោយឈរលើស្មារតីទទួលខុសត្រូវ និងពង្រឹងអនុលោមភាពនៃការអនុវត្តវិធាន-ការនេះ គឺជាមូលដ្ឋានគ្រឹះនៃការរស់នៅ និងដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចប្រកប ដោយសុវត្ថិភាព និងនិរន្តរភាព ។
- **កម្រិត ទី២ (មធ្យមៈ បង្កើនការប្រុងប្រយ័ត្ន)**៖ ស្ថានភាពនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ បានកើនឡើង ប៉ុន្តែស្ថិតនៅក្រោមការគ្រប់គ្រងបាន និងប្រព័ន្ធសុខាភិបាលមានសមត្ថភាពគ្រប់គ្រាន់ ។ ទោះជាដូច្នេះក្តី, ក្នុងស្មារតីបុរេសកម្ម អាចធ្វើការសម្រេចចិត្តដាក់ចេញនូវឱ្យអនុវត្តនូវវិធានការបន្ថែមសមស្រប និងចាំបាច់ ជាពិសេស នៅតាមភូមិសាស្ត្រ ឬទីតាំងសកម្មភាពសង្គម-សេដ្ឋ-កិច្ចណាដែលត្រូវបានចាត់ទុកថាប្រឈមនឹងហានិភ័យខ្ពស់នៃការឆ្លងរាលដាល ។ វិធានការបន្ថែមនេះ គប្បីមិនសូវបង្កនូវផលវិបាក និងប៉ះពាល់ ដល់ការរស់នៅ និងដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចប្រចាំថ្ងៃ ។
- **កម្រិត ទី៣ (ខ្ពស់ៈ ព្រមានទុកជាមុន)**៖ ស្ថានភាពនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ នៅតែបន្តកើនឡើង ហើយសមត្ថភាពនៃប្រព័ន្ធសុខាភិបាលកំពុងឈានទៅជិត "បន្ទាត់ក្រហម" ដូច្នេះ ត្រូវធ្វើការសម្រេចចិត្តលើការបង្កើនសមត្ថភាពព្យាបាល និងថែទាំ (អគារ, គ្រែ, ឱសថ-បរិក្ខារ, ឧបករណ៍ពេទ្យ, ក្រុមគ្រូពេទ្យ-បុគ្គលិក, ភស្តុភារ ជាដើម) និងការដាក់ឱ្យអនុវត្តវិធានការបន្ថែមទៀត ដែលមិនបង្កនូវផលវិបាក ឬ ផលប៉ះពាល់**ច្រើន** ដល់ការរស់នៅ និងដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចប្រចាំថ្ងៃ។
- **កម្រិត ទី៤ (ខ្ពស់ខ្លាំងៈ ប្រកាសអាសន្ន)**៖ ស្ថានភាពនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ចេះតែបន្តកើនឡើងជាលំដាប់ និងអាចឈានដល់ស្ថានភាពដែលមិនអាចគ្រប់គ្រងបាន ហើយប្រព័ន្ធសុខាភិបាល ក៏អស់សមត្ថភាពទទួលរ៉ាប់រង ឬនិយាយម្យ៉ាងទៀតថា បានឈានដល់ ឬហួស "បន្ទាត់ក្រហម" ដូច្នេះចាំបាច់ត្រូវធ្វើការសម្រេចចិត្តដាក់ឱ្យអនុវត្តនូវវិធានការសុខាភិបាល, រដ្ឋបាល និងវិធានការចាំបាច់នានាច្រើនថែមទៀត ដែលមានលក្ខណៈ រឹតត្បិត និងតឹងតែង និងប៉ះពាល់ធ្ងន់ធ្ងរដល់ការរស់នៅ និងដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចប្រចាំថ្ងៃ (ឧ. ការបិទខ្ទប់) ដើម្បីគ្រប់គ្រងសភាពការណ៍មកវិញ ។

**<u>កំណត់សម្គាល់</u>៖** សូចនាករខាងក្រោមអាចត្រូវយកមកប្រើប្រាស់បន្ថែម សម្រាប់ការតាមដាននិន្នាការនៃការចម្លង និងកម្រិតសមត្ថភាពនៃប្រព័ន្ធសុខាភិបាលៈ

- អត្រាអ្នកជំងឺកូវីដ-១៩ ជាសះស្បើយក្នុង ១០០ ករណីដែលបានទទួលការព្យាបាល

- ចំនួនករណីជំងឺកូវីដ-១៩ ថ្មី ក្នុងចំណោមប្រជាជន ១០០.០០០នាក់
- អត្រាវិជ្ជមាននៃតេស្តរកមេរោគកូវីដ-១៩ នៅតាមទីតាំងអង្កេតឃ្លាំមើល (Sentinel surveillance sites) ក្នុងរយៈពេល ១៤ថ្ងៃ
- អត្រាប្រើប្រាស់គ្រែ ICU (ដោយមិនរាប់បញ្ចូលគ្រែអ្នកជំងឺកូវីដ-១៩) នៅមន្ទីរពេទ្យ/មណ្ឌលព្យាបាល
- ចំនួនបុគ្គលិក ICU ក្នុងចំណោមប្រជាជន ១០០.០០០ នាក់
- អត្រាប្រើប្រាស់គ្រែទូទៅ (ដោយមិនរាប់បញ្ចូលគ្រែអ្នកជំងឺកូវីដ-១៩) នៅមន្ទីរពេទ្យ/មណ្ឌលព្យាបាល
- អត្រាចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ។

## បរិសិដ្ឋទី៥. ក្របខណ្ឌបច្ចេកទេសសម្រាប់រៀបចំ និងអនុវត្តផែនការសកម្មភាព

### គោលដៅទី១. ការពារអាយុជីវិត និងសុវត្ថិភាពនៃការរស់នៅ និងការចូលរួមក្នុងសកម្មភាពសង្គម-សេដ្ឋកិច្ច របស់ប្រជាពលរដ្ឋគ្រប់រូប

| យុទ្ធសាស្ត្រ<br>និងវិធានយុទ្ធសាស្ត្រ | ការទទួលខុសត្រូវ<br>លើការអនុវត្ត |
|---|---|
| *យុទ្ធសាស្ត្រទី១. រក្សាភាពស៊ាំសហគមន៍រឹងមាំជាប្រចាំប្រឆាំងនឹងមេរោគកូវីដ-១៩ ជាពិសេសមេរោគបំប្លែងខ្លួនថ្មី។* | |
| • ជំរុញលើកទឹកចិត្ត និងជួយសម្រួល ឱ្យប្រជាពលរដ្ឋ មន្ត្រី បុគ្គលិក, កម្មករ-និយោជិត ចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ តាមរបបចាក់វ៉ាក់សាំង និងតាមពេលវេលា ដែលត្រូវបានកំណត់ដោយក្រសួងសុខាភិបាល ។ | • ក្រសួង-ស្ថាប័ន, អង្គភាព និងគ្រឹះស្ថានអាជីវកម្ម[2]<br>• អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់<br>• គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩),<br>• អនុគណៈកម្មការអប់រំបណ្តុះ-បណ្តាលនិងទំនាក់ទំនងសាធារណៈ និងយន្តការពាក់ព័ន្ធ[3] |
| • ពិនិត្យស្ថានភាពចាក់វ៉ាក់សាំងរបស់អ្នកជំងឺ/អតិថិជន ដែលមកទទួលសេវាសុខភាព និងផ្តល់ការប្រឹក្សា និងជួយសម្រួលឱ្យបុគ្គលដែលមិនបានចាក់វ៉ាក់សាំងទៅចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ បើសិនបុគ្គលនោះមានលក្ខណៈសម្បត្តិសមស្របតាមលក្ខណៈវិនិច្ឆ័យនៃការចាក់វ៉ាក់សាំង ។ | • មន្ទីរពេទ្យ និងមណ្ឌលសុខភាព និងអ្នកផ្តល់សេវាសុខាភិបាលឯកជន |
| • វាយតម្លៃស្ថានភាពអត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងតាមភូមិសាស្ត្រ និងទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ច ដែលមានផ្ទុះជំងឺកូវីដ-១៩ នៅ ពេលស្រាវជ្រាវរកករណី/ចង្កោមករណី និងបញ្ចូលរបាយការណ៍ពីស្ថានភាពចាក់-វ៉ាក់សាំងនៅក្នុងរបាយការណ៍ស្រាវជ្រាវករណី/ចង្កោមករណី ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• អនុគណៈកម្មការឆ្លើយតបបន្ទាន់និងស្រាវជ្រាវរកបុគ្គលផ្ទុកមេរោគកូវីដ-១៩ និងយន្តការដែលពាក់ព័ន្ធ |
| • បញ្ចូលការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទៅក្នុងកម្ម-វិធីជាតិផ្តល់ថ្នាំបង្ការ នៃក្រសួងសុខាភិបាល ដើម្បីឆ្លើយតបនឹងតម្រូវការនៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ | • ក្រសួងសុខាភិបាល<br>• គ.វ.ក-១៩<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• យន្តការដែលមានការពាក់ព័ន្ធ |

[2] *គ្រឹះស្ថាន និងអាជីវកម្ម* ទាំងក្នុងវិស័យសាធារណៈ និងឯកជន

[3] *យន្តការដែលមានការពាក់ព័ន្ធ* រាប់បញ្ចូលទាំង គណៈកម្មការ, អនុគណៈកម្មការ និងយន្តការនានាចំណុះឱ្យ គ.ប.ក និង/ឬ គ.អ.ក

| | |
|---|---|
| ជូស ជំរុញ ជាបន្តបន្ទាប់ តាមការចាំបាច់ក្នុងពេលអនាគត ។ | |
| • បំលែងប្រព័ន្ធកត់ត្រាចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ (vaccine.gov.kh) ឱ្យទៅជា “ប្រព័ន្ធគ្រប់គ្រងការចាក់វ៉ាក់សាំង” ដោយរាប់បបញ្ចូលទាំងវ៉ាក់សាំងដែលមាននៅក្នុងបញ្ជីវ៉ាក់សាំងនៃកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ។ ប្រព័ន្ធនេះត្រូវដាក់ឱ្យប្រើប្រាស់ទាំងក្នុងវិស័យសុខាភិបាលសាធារណៈ និងឯកជន ។ | • ក្រសួងសុខាភិបាល<br>• គ.វ.ក-១៩, អនុគណៈកម្មការបច្ចេកវិទ្យា និងទិន្នន័យ និងយន្តការពាក់ព័ន្ធ |
| **យុទ្ធសាស្ត្រទី២.** តាមដាន វាយតម្លៃ និងសិក្សាស្រាវជ្រាវអំពីប្រសិទ្ធភាពនៃវ៉ាក់សាំងកូវីដ-១៩ ដើម្បីគាំទ្រដល់ការពិនិត្យកែសម្រួលយុទ្ធសាស្ត្រចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឬវិធានការពាក់ព័ន្ធចាំបាច់នានា។ | |
| • តាមដាននិន្នាការវិវត្តនៃមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មីដែលមានសមត្ថភាពបំផ្លាញប្រសិទ្ធភាពវ៉ាក់សាំង និងបង្កភាពធ្ងន់ធ្ងរដល់ជំងឺ ។ | • ក្រសួងសុខាភិបាល/ក្រុមការងារជំនាញ<br>• គ.វ.ក-១៩, អនុគណៈកម្មការសេវាមន្ទីរពិសោធន៍ និងយន្តការពាក់ព័ន្ធ<br>• រដ្ឋបាលរាជធានី-ខេត្ត |
| • ធ្វើការស្រាវជ្រាវឯកសារ/របបគំហើញបែបវិទ្យាសាស្ត្រស្តីពីរបបចាក់វ៉ាក់សាំង, ប្រសិទ្ធភាព និងភាពស៊ាំសហគមន៍ ។ | • ក្រសួងសុខាភិបាល/ក្រុមការងារជំនាញ<br>• គ.វ.ក-១៩ និងយន្តការពាក់ព័ន្ធ |
| • រៀបចំ និងធ្វើការសិក្សាស្រាវជ្រាវពីប្រសិទ្ធភាពនៃវ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ នៅក្នុងបរិបទកម្ពុជា ។ | • ក្រសួងសុខាភិបាល/ក្រុមការងារជំនាញ<br>• គ.វ.ក-១៩ និងយន្តការពាក់ព័ន្ធ |
| **យុទ្ធសាស្ត្រទី៣.** រក្សាការប្រាស្រ័យទាក់ទងហានិភ័យ និងទំនាក់ទំនងសាធារណៈ ប្រកបដោយប្រសិទ្ធភាព និងទាន់ពេល ជាពិសេសក្នុងករណីមានការឆ្លងរាលដាល ក្នុងទ្រង់ទ្រាយធំ។ | |
| • លើកកម្ពស់ការយល់ដឹង និងការអនុវត្តរបស់ប្រជាពលរដ្ឋ និងសាធារណជន អំពីរបៀបរស់នៅតាមគន្លងប្រក្រតីភាពថ្មី ឱ្យក្លាយជាទម្លាប់ធម្មតា ដូចជា វិធាន "៣ ការពារ កុំ ៣ ", ការប្រើប្រាស់ QR Code (STOP-COVID-19) ជាដើម ជាពិសេស នៅក្នុងស្ថានភាពដែលការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅតែជាហានិភ័យចម្បងនៃសុខភាពសាធារណៈ ។ | • ក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធ<br>• រដ្ឋបាលរាជធានី-ខេត្ត, អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ<br>• អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ/ពង្រឹងការអនុវត្តច្បាប់ និងយន្តការពាក់ព័ន្ធ |
| • ផ្តល់ព័ត៌មាន ឬសារចាំបាច់នានា ច្បាស់លាស់ និងដោយតម្លាភាព តាមរយៈបណ្តាញផ្សព្វផ្សាយសង្គម ឬបណ្តាញសហគមន៍ដែលគួរឱ្យទុកចិត្ត ដើម្បីបង្កើនភាពជឿជាក់លើការគ្រប់គ្រងវិបត្តិនៃជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាល ។ | • ក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធ<br>• រដ្ឋបាលរាជធានី-ខេត្ត, អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ<br>• អនុគណៈកម្មការអប់រំ បណ្តុះបណ្តាលនិងទំនាក់ទំនងសាធារណៈ និងយន្តការពាក់ព័ន្ធ |

| | |
|---|---|
| • គ្រប់គ្រងព័ត៌មានមិនច្បាស់លាស់ និងព័ត៌មានក្លែងក្លាយ ដែលធ្វើឱ្យសាធារណជនមានការភ័ន្តច្រឡំ ឬភ័យខ្លាច និងចាត់វិធានការឆ្លើយតប ឬលុបបំបាត់ឱ្យទាន់ពេល ។ | • ក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធ<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ និងយន្តការពាក់-ព័ន្ធ |
| • ពង្រីកការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន/ឌីជីថល ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទងហានិភ័យ និងទំនាក់ទំនងសាធារណៈ ។ | • ក្រសួង-ស្ថាប័ន, អង្គភាព, គ្រឹះស្ថាន និងអាជីវកម្ម<br>• រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• អនុគណៈកម្មការអប់រំ បណ្តុះបណ្តាលនិងទំនាក់ទំនងសាធារណៈ/ បច្ចេកវិទ្យា និងទិន្នន័យ និងយន្តការពាក់ព័ន្ធ |
| **យុទ្ធសាស្ត្រទី៤៖** ពង្រឹងអនុលោមភាព នៃការអនុវត្តវិធានសុវត្ថិភាព, វិធានការសុខាភិបាល រដ្ឋបាល និងច្បាប់ នៅក្នុងសហគមន៍ និងទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ច។ | |
| • តាមដានត្រួតពិនិត្យ និងធ្វើអធិការកិច្ច/អភិបាលកិច្ចអនុលោមភាពនៃការអនុវត្តវិធានការ នៅកន្លែងធ្វើការ/ទី-តាំងនៃសកម្មភាពសង្គម-សេដ្ឋកិច្ច ដើម្បីធ្វើការកែលម្អឱ្យបានទាន់ពេល ក្នុងករណីដែលការអនុវត្តនៅមិនទាន់គ្រប់គ្រាន់ ។ | • ក្រសួង-ស្ថាប័ន, អង្គភាពដែលពាក់ព័ន្ធ<br>• រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• អនុគណៈកម្មការពង្រឹងការអនុវត្តច្បាប់ និងយន្តការពាក់ព័ន្ធ |
| • ជំរុញសហគមន៍ និងសាធារណជន ឱ្យចូលរួមយ៉ាងសកម្មក្នុងស្មារតីទទួលខុសត្រូវ ក្នុងការពង្រឹងអនុលោមភាពនៃការអនុវត្តវិធានសុវត្ថិភាព នៅក្នុងសហគមន៍ និងតាមទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ច តាមរយៈការគ្រប់គ្រងការប្រាស្រ័យទាក់ទងគ្នា និងទំនាក់ទំនងសាធា-រណៈដែលមានក្នុងសហគមន៍ និងទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ចដូចជា ក្រុមទ្រទ្រង់សុខភាពភូមិ, ការចុះផ្តល់សេវាសុខាភិបាលតាមមូលដ្ឋាន ប្រព័ន្ធ Hot lines ជាដើម ។ | • ក្រសួង-ស្ថាប័ន, អង្គភាព, គ្រឹះស្ថាន និងអាជីវកម្ម<br>• រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• អនុគណៈកម្មការអប់រំ បណ្តុះបណ្តាលនិងទំនាក់ទំនងសាធារណៈ និងយន្តការពាក់-ព័ន្ធនានា<br>• បណ្តាញផ្សព្វផ្សាយ |

## គោលដៅទី២. ពង្រឹងសមត្ថភាពស្នូលនៃប្រព័ន្ធសុខាភិបាល ដើម្បីបង្ការ និងគ្រប់គ្រងការឆ្លងរាលដាលជំងឺកូវីដ-១៩ ផង និងផ្តល់សេវាសុខាភិបាលជាសារវ័ន្តជាប្រចាំផង។

| យុទ្ធសាស្ត្រ<br>និងវិធានយុទ្ធសាស្ត្រ | ការទទួលខុសត្រូវ<br>លើការអនុវត្ត |
|---|---|
| **យុទ្ធសាស្ត្រទី៥.** គ្រប់គ្រងច្រកចេញ-ចូលប្រទេស ដើម្បីទប់ស្កាត់ការនាំចូលមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មី ដែលអាចបំផ្លាញប្រសិទ្ធភាពវ៉ាក់សាំង និងបង្គ្រោះថ្នាក់កាចសាហាវឆ្លងចូលក្នុងសហគមន៍ ។ ។ | |
| • ធ្វើបច្ចុប្បន្នភាពគោលការណ៍សម្រាប់អ្នកដំណើរក្រៅប្រទេសចូលមកក្នុងប្រទេសកម្ពុជា ស្របតាមស្ថានការណ៍វិវត្តក្នុង | • ក្រសួងសុខាភិបាល |

| | |
|---|---|
| តំបន់ ឬក្នុងសកលលោក ដូចជាការលេចឡើងនៃមេរោគបំប្លែងខ្លួនថ្មីដែលកាចសាហាវ និន្នាការនៃការឆ្លងរាលដាល ស្ថានភាពនៃវ៉ាក់សាំង ជាដើម ។ | • អនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក និងយន្តការដែលមានការពាក់ព័ន្ធ |
| • ពង្រឹងការងារចត្តាឡីស័កនៅតាមច្រកទ្វារចេញ-ចូលប្រទេស (ផ្លូវអាកាស, ផ្លូវគោក និងផ្លូវទឹក) ដោយធ្វើការពិនិត្យ/ធ្វើអធិការកិច្ចលើយានយន្តដឹកជញ្ជូន និងពិនិត្យអ្នកបើកបរ/ក្រុមនាវិក ដើម្បីស្វែងរកសញ្ញាហានិភ័យសុខភាពសាធារណៈ, ការបង្ករោគ ឬការចម្លងនៃជំងឺឆ្លង ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត/ក្រុមមន្ត្រីចត្តាឡីស័កនៅតាមច្រកទ្វារចេញ-ចូលប្រទេស<br>• អនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេសនិងការធ្វើចត្តាឡីស័ក |
| • ធ្វើតេស្តវិភាគរកប្រភេទវីរុសកូវីដ-១៩បំប្លែងខ្លួនថ្មី (Genome Sequencing) និងចាត់វិធានការសមស្របនានា ដើម្បីទប់ស្កាត់ការចម្លងចូលក្នុងសហគមន៍ ។ | • ក្រសួងសុខាភិបាល<br>• អនុគណៈកម្មការសេវាមន្ទីរពិសោធន៍ និងយន្តការពាក់ព័ន្ធ |
| **យុទ្ធសាស្ត្រទី៦.** បង្ការ, កាត់បន្ថយ និងគ្រប់គ្រងការផ្ទុះឆ្លងរាលដាលនៅតាមទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ច ព្រមទាំងកាត់បណ្តាញចម្លងពីសហគមន៍មួយ ទៅសហគមន៍មួយទៀត ។ | |
| • តាមដាន និងវាយតម្លៃហានិភ័យសុខភាពសាធារណៈ ជាប្រចាំ ដោយប្រើប្រាស់ព័ត៌មានពីប្រភពចម្រុះ ដោយរាប់បញ្ចូលទាំងការចុះធ្វើអង្កេតផ្ទាល់នៅក្នុងភូមិសាស្ត្រ/ទីតាំងដែលមានផ្ទុះការចម្លង ដើម្បីដាក់ចេញនូវវិធានការឆ្លើយតបចំគោលដៅ និងទាន់ពេល ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ<br>• អនុគណៈកម្មការវាយតម្លៃ, ផែនការ និងយុទ្ធសាស្ត្រ/ឆ្លើយតបបន្ទាន់និងស្រាវជ្រាវរកបុគ្គលផ្ទុកមេរោគកូវីដ-១៩ និងយន្តការដែលមានការពាក់ព័ន្ធ |
| • តាមដាន និងវាយតម្លៃសមត្ថភាពមន្ទីរពេទ្យ/មណ្ឌលព្យាបាលជាប្រចាំ និងរៀបចំធ្វើបច្ចុប្បន្នភាពផែនការត្រៀម/បម្រុងធនធានចាំបាច់នានា ដូចជា អគារ, ឱសថ-បរិក្ខារ, ឧបករណ៍ពេទ្យ/សង្គ្រោះ, គ្រូពេទ្យ-បុគ្គលិក ជាដើមដើម្បីឆ្លើយតបនឹងតម្រូវការនៃសេវាព្យាបាល និងថែទាំ ជាពិសេសសេវាសង្គ្រោះបន្ទាន់កម្រិតមធ្យមនិងធ្ងន់ ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• អនុគណៈកម្មការបច្ចេកទេសនិងព្យាបាល/វាយតម្លៃផែនការនិងយុទ្ធ-សាស្ត្រ/ផ្គត់ផ្គង់និងហិរញ្ញវត្ថុ/សាងសង់និងជួសជុល និងយន្តការពាក់ព័ន្ធ |
| • រក្សាភាពបុរេសកម្ម និងសកម្ម នៃប្រព័ន្ធអង្កេតតាមដាន ទាំងជំងឺកូវីដ-១៩ ជំងឺផ្លូវដង្ហើមផ្នែកខាងក្រោមស្រួចស្រាវ និងជំងឺរលាកសួត នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• យន្តការពាក់ព័ន្ធ |
| • រក្សាភាពបុរេសកម្ម និងសកម្ម នៃប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ ដើម្បីធ្វើការសម្របសម្រួលមានប្រសិទ្ធភាពរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការដាក់ចេញនូវវិធានការឆ្លើយតបនៅពេលមានការផ្ទុះឆ្លងទ្រង់ទ្រាយធំ ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• យន្តការពាក់ព័ន្ធ |
| • បង្កើនសមត្ថភាព និងកិច្ចដំណើរការនៃប្រព័ន្ធ hotline ដើម្បីជូនដំណឹង ឬផ្តល់ការណែនាំចាំបាច់នានា និងទទួលព័ត៌មាន/ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត |

| | |
|---|---|
| ការរាយការណ៍ពីសាធារណជន បានទូលំទូលាយ និងទាន់ពេល ដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន/ឌីជីថល ។ | • អនុគណៈកម្មការបច្ចេកវិទ្យានិងទិន្នន័យនិងយន្តការដែលមានការពាក់-ព័ន្ធ |
| • ពង្រឹងការគ្រប់គ្រងប្រព័ន្ធព័ត៌មានសុខាភិបាល និងប្រព័ន្ធរាយការណ៍ នៅគ្រប់លំដាប់ថ្នាក់ ដើម្បីប្រមូលទិន្នន័យ/ព័ត៌មានត្រឹមត្រូវ គួរទុកចិត្ត និងទាន់ពេល សម្រាប់ការតាមដាននិងវាយតម្លៃស្ថានការណ៍វិវត្តនៃជំងឺកូវីដ-១៩ ដោយរាប់បញ្ចូលទាំងហានិភ័យនិងសមត្ថភាពប្រព័ន្ធសុខាភិបាល ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• អនុគណៈកម្មការបច្ចេកវិទ្យានិងទិន្នន័យ-គ.អ.ប. និងយន្តការដែលមានការពាក់ព័ន្ធ |
| • បង្កើនសមត្ថភាពមន្ទីរពិសោធន៍ ក្នុងការធ្វើតេស្តរកមេរោគកូវីដ-១៩ ជាពិសេស ក្នុងករណីមានការផ្ទុះ ក្នុងទ្រង់ទ្រាយធំ នៅក្នុងទីកន្លែងការងារ/ទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ច និងសហគមន៍ ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• អនុគណៈកម្មការសេវាមន្ទីរពិសោធន៍ និងយន្តការដែលមានការពាក់ព័ន្ធ |
| • ធ្វើតេស្តលើរាល់ករណីសង្ស័យទាំងអស់ ឱ្យបានលឿនក្នុងទីកន្លែងការងារ/ទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ច ឬភូមិសាស្ត្រដែលផ្ទុះជំងឺកូវីដ-១៩ ដើម្បីកំណត់រកករណីវិជ្ជមានឱ្យបានលឿន ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• អនុគណៈកម្មការឆ្លើយតបបន្ទាន់ និងស្រាវជ្រាវរកបុគ្គលផ្ទុកមេរោគកូវីដ-១៩ និងយន្តការពាក់ព័ន្ធ<br>• រដ្ឋបាល/សហគមន៍/ប្រធាន/ម្ចាស់ទី-កន្លែងការងារ/ទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ច ត្រូវចូលរួមសហការជាមួយរដ្ឋបាលសុខាភិបាល |
| • ស្រាវជ្រាវរកឃើញឱ្យបានឆាប់ករណី/ចង្កោមករណីជំងឺកូវីដ-១៩ និងឆ្លើយតបឱ្យបានរហ័ស និងចំគោលដៅ ដើម្បីទប់-ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាល ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ<br>• អនុគណៈកម្មការឆ្លើយតបបន្ទាន់ និងស្រាវជ្រាវរកបុគ្គលផ្ទុកមេរោគកូវីដ-១៩ និងយន្តការដែលមានការពាក់ព័ន្ធ |
| • ស្វែងរកអ្នកប៉ះពាល់ ជាមួយអ្នកជំងឺកូវីដ-១៩ ឱ្យបានលឿន និងដាក់ឱ្យធ្វើចត្តាឡីស័កនៅផ្ទះ ឬនៅមណ្ឌលចត្តាឡីស័កអនុលោមតាមនីតិវិធីប្រតិបត្តិស្តង់ដារ ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ<br>• អនុគណៈកម្មការឆ្លើយតបបន្ទាន់ និងស្រាវជ្រាវរកបុគ្គលផ្ទុកមេរោគកូវីដ-១៩ និងយន្តការដែលមានការពាក់ព័ន្ធ |
| • ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស/គ្លីនិក ដោយរាប់បញ្ចូលទាំងការគាំពារផ្នែកសុខភាពផ្លូវចិត្ត ដល់មណ្ឌល/សណ្ឋាគារចត្តា-ឡីស័ក និងតាមផ្ទះ និងតាមដានត្រួតពិនិត្យអនុលោមភាពនៃការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារ ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត |

| | |
|---|---|
| | • អនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក/បច្ចេកទេសនិងព្យាបាល |
| **យុទ្ធសាស្ត្រទី៧.** បង្កើនសមត្ថភាពផ្តល់សេវាបង្ការ, សេវាធ្វើរោគវិនិច្ឆ័យ, ព្យាបាល និងថែទាំ ដែលមានគុណភាព, សុវត្ថិភាព និងប្រសិទ្ធភាព ជាពិសេសក្នុងករណីមានការផ្ទុះឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងទ្រង់ទ្រាយធំ ដែលនាំឱ្យកើនឡើងនូវការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ និងការបាត់បង់អាយុជីវិត។ | |
| • ស្វះស្វែងរកឱសថដែលសក្តិសិទ្ធ វិធីសាស្ត្រព្យាបាល/បច្ចេកវិទ្យាថ្មី ដែលមានប្រសិទ្ធភាពខ្ពស់ សម្រាប់ការព្យាបាល និងថែទាំអ្នកជំងឺកូវីដ-១៩ ។ | • ក្រសួងសុខាភិបាល<br>• អនុគណៈកម្មការបច្ចេកទេសនិងព្យាបាល<br>• វិស័យឯកជន |
| • ធ្វើបច្ចុប្បន្នភាព និងអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារ ស្តីការព្យាបាល និងថែទាំជំងឺកូវីដ-១៩ តាមការចាំបាច់ ។ | • ក្រសួងសុខាភិបាល<br>• អនុគណៈកម្មការបច្ចេកទេសនិងព្យាបាល |
| • ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស/គ្លីនិក ដោយរាប់បញ្ចូលទាំងការគាំពារផ្នែកសុខភាពផ្លូវចិត្ត ដល់នៅមន្ទីរពេទ្យ/មណ្ឌលព្យាបាលរដ្ឋ/ឯកជន និងតាមផ្ទះ និងតាមដានត្រួតពិនិត្យអនុលោមភាពនៃការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារ ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• អនុគណៈកម្មការបច្ចេកទេសនិងព្យាបាល |
| • តាមដានការអនុវត្តវិធានបង្ការ និងគ្រប់គ្រងការឆ្លងរោគ នៅមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន ដើម្បីទប់ស្កាត់ជំងឺឆ្លងនានា ជាពិសេសជំងឺកូវីដ-១៩ ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• យន្តការដែលមានការពាក់ព័ន្ធ |
| • ពង្រឹងប្រព័ន្ធបញ្ជូន ទាំងអ្នកជំងឺទូទៅ ទាំងអ្នកជំងឺកូវីដ-១៩ ដែលនៅសម្រាកព្យាបាលតាមផ្ទះ/សណ្ឋាគារ/សេវាឯកជន ដោយត្រៀម រថយន្តគិលានសង្គ្រោះដែលមានឧបករណ៍បរិក្ខារពេទ្យ មធ្យោបាយទំនាក់ទំនង និងក្រុមគ្រូពេទ្យ-បុគ្គលិក សម្រាប់ការបញ្ជូនអ្នកជំងឺឱ្យបានឆាប់ ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• អនុគណៈកម្មការបច្ចេកទេសនិងព្យាបាល<br>• អ្នកផ្តល់សេវាសុខាភិបាលឯកជន |
| • រក្សាការផ្តល់សេវាព្យាបាល និងថែទាំជាសារវន្ត ជាប្រចាំ (ក្រៅពីសេវាព្យាបាលនិងថែទាំអ្នកជំងឺកូវីដ-១៩) ដល់ប្រជាពលរដ្ឋទូទៅ ជាពិសេស នៅក្នុងករណីដែលមានការផ្ទុះឆ្លងរាលដាលជំងឺកូវីដ-១៩ ក្នុងទ្រង់ទ្រាយធំ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• អនុគណៈកម្មការបច្ចេកទេសនិងព្យាបាល/ផ្គត់ផ្គង់ហិរញ្ញវត្ថុ |
| • បង្កើនការវិនិយោគលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន/ឌីជីថល ដូចជា កម្មវិធីទូរស័ព្ទដៃ (Mobile App) ជាប្រព័ន្ធរាយការណ៍អំពីស្ថានភាពសុខភាពបុគ្គលនិងប្រព័ន្ធអេឡិចត្រូនិក (telemedicine) សម្រាប់ការពិគ្រោះជំងឺនិង/ឬផ្តល់ការព្យាបាលពីចម្ងាយ និងការប្រាស្រ័យទាក់ទងផ្នែកបច្ចេកទេស/គ្លីនិក រវាងមន្ទីរពេទ្យថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត។ | • ក្រសួងសុខាភិបាល<br>• មន្ទីរពេទ្យជាតិ<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• អនុគណៈកម្មការបច្ចេកទេសនិងព្យាបាល/បច្ចេកវិទ្យានិងទិន្នន័យ |

| | |
|---|---|
| | |
| **យុទ្ធសាស្ត្រទី៨.** កសាងភាពជាដៃគូរវាងផ្នែកសាធារណៈ និងឯកជន ក្នុងការលើកកម្ពស់សេវា បង្ការ ព្យាបាល និងថែទាំអ្នកជំងឺកូវីដ-១៩ ដោយឈរលើគោលការណ៍នៃតុល្យភាព រវាងផលប្រយោជន៍សុខភាពសាធារណៈ និងធុរកិច្ច ។ | |
| • ពង្រីកបណ្ដាញព្យាបាលអ្នកជំងឺកូវីដ-១៩ នៅក្នុងវិស័យឯកជន និងធានានូវគុណភាព សុវត្ថិភាព និងសក្ដិសិទ្ធិភាពនៃការព្យាបាលនិងថែទាំ។ | • ក្រសួងសុខាភិបាល<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• អនុគណៈកម្មការបច្ចេកទេសនិងព្យាបាល |
| • ផ្ដល់ការគាំទ្រ និងបើកទូលាយដល់សេវាសុខាភិបាលឯកជនចូលរួមឱ្យបានពេញលេញលើការផ្គត់ផ្គង់ឱសថ-បរិក្ខារ និងបច្ចេកវិទ្យាថ្មីសម្រាប់ការព្យាបាលជំងឺកូវីដ-១៩ និងការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក្នុងថ្លៃសមរម្យ ។ | • ក្រសួងសុខាភិបាល, ក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• អនុគណៈកម្មការបច្ចេកទេសនិងព្យាបាល/ផ្គត់ផ្គង់ហិរញ្ញវត្ថុ និង គ.វ.ក-១៩<br>• យន្តការដែលមានការពាក់ព័ន្ធ ដោយរាប់បញ្ចូលទាំងយន្តការរវាងរដ្ឋ-ឯកជន |
| • វាយតម្លៃពីសក្ដានុពលភាពនៃវិស័យឯកជនក្នុងការវិនិយោគលើការផលិតក្នុងស្រុកនូវផលិតផលវេជ្ជសាស្ត្រដែលជាតម្រូវការចាំបាច់សម្រាប់ការបង្ការព្យាបាល និងថែទាំអ្នកជំងឺកូវីដ-១៩ ដូចជាឱសថ,សម្ភារៈ និងបរិក្ខារពេទ្យ ជាដើម ស្របតាមឧត្តមានុភាពនៃការផលិត (Good Manufacturing Practices)។ | • ក្រសួង-ស្ថាប័ន និងយន្តការដែលមានការពាក់ព័ន្ធដោយរាប់បញ្ចូលទាំងយន្តការរវាងរដ្ឋ-ឯកជន |

## គោលដៅទី៣. ក្សោកិច្ចដំណើរការឡើងវិញនៃសកម្មភាពសង្គម-សេដ្ឋកិច្ច ប្រកបដោយសុវត្ថិភាព និងនិរន្តរភាព

| យុទ្ធសាស្ត្រ និងវិធានយុទ្ធសាស្ត្រ | ការទទួលខុសត្រូវលើការអនុវត្ត |
|---|---|
| **យុទ្ធសាស្ត្រទី៩.** បង្ការ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ព្រមទាំងការផ្ទុះឆ្លងរាលដាលតាមទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ច ក្នុងវិស័យ និងអនុវិស័យនីមួយៗ ។ | |
| • ការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រ ឬផែនការសកម្មភាព ឬផែនទីបង្ហាញផ្លូវសម្រាប់ការបើកដំណើរការឡើងវិញ តាមវិសេសភាពនៃវិស័យ ឬអនុវិស័យ ឬប្រភេទសកម្មភាពសង្គមសេដ្ឋកិច្ច។ | • ក្រសួង-ស្ថាប័នទទួលបន្ទុកតាមវិស័យ/អនុវិស័យ<br>• អនុគណៈកម្មការវាយតម្លៃ ផែនការ និងយុទ្ធសាស្ត្រ និងយន្តការដែលពាក់ព័ន្ធ |

| | |
|---|---|
| • សម្របវិធានសុវត្ថិភាព ស្របតាមស្ថានភាពប្រែប្រួលនៃកម្រិតហានិភ័យសុខភាពសាធារណៈដែលត្រូវបានជូនដំណឹងដោយក្រសួង-ស្ថាប័នសាធារណៈ ឬអាជ្ញាធរមានសមត្ថកិច្ច។ | • សាមីក្រសួង-ស្ថាប័ន, អង្គភាព, គ្រឹះស្ថាន និងអាជីវកម្ម |
| • រៀបចំ និងអនុវត្តវិធានសុវត្ថិភាព និងគ្រប់គ្រងហានិភ័យនៅនឹង កន្លែង ឬនីតិវិធីប្រតិបត្តិស្តង់ដារ ។ វិធានសុវត្ថិភាព និងគ្រប់គ្រងហានិភ័យ ឬនីតិវិធីប្រតិបត្តិស្តង់ដារទាំងនោះ ត្រូវពិនិត្យនិងធ្វើការកែសម្រួល តាមស្ថានភាពជាក់ស្តែង ។ | • សាមីក្រសួង-ស្ថាប័ន អង្គភាព គ្រឹះស្ថាន និងអាជីវកម្ម |
| • រក្សាបរិស្ថានអនាម័យល្អជាប្រចាំក្នុងទីកន្លែងធ្វើការ/ទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ច និងបរិវេណជុំវិញ ដូចជា លាងសម្អាត បាញ់ទឹកសម្លាប់មេរោគ រក្សាពន្លឺ និងចរន្តខ្យល់ចេញ-ចូលគ្រប់គ្រាន់ ជាដើម ។ | • សាមីក្រសួង-ស្ថាប័ន អង្គភាព គ្រឹះស្ថាន និងអាជីវកម្ម<br>• អនុគណៈកម្មការគ្រប់គ្រង និងចាត់ចែងសាកសពអ្នកជំងឺកូវីដ-១៩ |
| • វាយតម្លៃហានិភ័យនៃការឆ្លងនៅក្នុងទីតាំង និងសម្របវិធានសុវត្ថិភាពដែលកំពុងត្រូវបានអនុវត្ត ស្របតាមលទ្ធផលនៃការវាយតម្លៃ ។ ក្នុងករណីចាំបាច់អាចភ្ជាប់វិធានសុវត្ថិភាពជាមួយនឹងវិធានរដ្ឋបាល និងវិធានសុវត្ថិភាពការងារ( ដូចជាការប្រើ-ប្រាស់ឧបករណ៍ការពារខ្លួន (PPE) ។ | • សាមីក្រសួង-ស្ថាប័ន អង្គភាព គ្រឹះស្ថាន និងអាជីវកម្ម<br>• ក្រសួង-ស្ថាប័នទទួលបន្ទុកវិស័យ/អនុ-វិស័យ<br>• អនុគណៈកម្មការឆ្លើយតបបន្ទាន់ និងស្រាវជ្រាវរកបុគ្គលផ្ទុកមេរោគកូវីដ-១៩ |
| • តាមដានត្រួតពិនិត្យអនុលោមភាពនៃការអនុវត្តវិធានសុវត្ថិ-ភាពនៅក្នុងទីកន្លែងធ្វើការ/ទីតាំងសកម្មភាពសកម្មភាពសង្គម-សេដ្ឋកិច្ច ដើម្បីធ្វើការកែលម្អឱ្យបានទាន់ពេលវេលា បើសិនការអនុវត្តវិធានការនៅមិនទាន់គ្រប់គ្រាន់ ។ | • សាមីក្រសួង-ស្ថាប័ន អង្គភាព គ្រឹះស្ថាន និងអាជីវកម្ម<br>• ក្រសួង-ស្ថាប័នទទួលបន្ទុកវិស័យ/អនុ-វិស័យ<br>• រដ្ឋបាលរាជធានី-ខេត្ត<br>• អនុគណៈកម្មការពង្រឹងការអនុវត្តច្បាប់ |
| • រៀបចំផែនការគ្រប់គ្រងហានិភ័យទុកជាមុន សម្រាប់ធ្វើការផ្លាស់ប្តូរវិធានការឆ្លើយតបជាបន្ទាន់ នៅពេលរកឃើញមានការចម្លងនៅក្នុងកន្លែងធ្វើការ/ទីតាំងសកម្មភាពសកម្មភាពសង្គម-សេដ្ឋកិច្ច ។ | • សាមីក្រសួង-ស្ថាប័ន អង្គភាព គ្រឹះស្ថាន និងអាជីវកម្ម<br>• ក្រសួង-ស្ថាប័នទទួលបន្ទុកវិស័យ/អនុ-វិស័យ, និងអនុគណៈកម្មការឆ្លើយតបបន្ទាន់និងស្រាវជ្រាវរកបុគ្គលផ្ទុកមេ-រោគកូវីដ-១៩/អនុគណៈកម្មការវាយ-តម្លៃ ផែនការ និងយុទ្ធសាស្ត្រ |
| **យុទ្ធសាស្ត្រទី១០.** ការពារមន្ត្រី, បុគ្គលិក, កម្មករ-និយោជិត ព្រមទាំងអតិថិជន ពីហានិភ័យនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។ | |
| • ផ្តល់ការអប់រំ និងបណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិក, កម្មករ-និយោជិតឱ្យបានយល់ច្បាស់ និងអនុវត្តវិធានសុវត្ថិភាព និងគ្រប់គ្រងហានិភ័យ ឬ នីតិវិធីប្រតិបត្តិស្តង់ដារ ដោយស្មារតីទទួលខុសត្រូវ។ | • សាមីក្រសួង-ស្ថាប័ន, អង្គភាព, គ្រឹះស្ថាន និងអាជីវកម្ម អនុវត្ត<br>• ក្រសួង-ស្ថាប័នទទួលបន្ទុកវិស័យ/អនុ-វិស័យ និងយន្តការដែលពាក់ព័ន្ធ |

| | |
|---|---|
| • សម្របសម្រួលឱ្យបុគ្គលដែលមិនបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ដោយសារតែបញ្ហាសុខភាពអាចបំពេញការងារបានផង និងរក្សាបានសុវត្ថិភាពក្នុងកន្លែងធ្វើការ/ទីតាំងផង ដូចជា ធ្វើការពីផ្ទះតាមប្រព័ន្ធអេឡិចត្រូនិក ពាក់ម៉ាស់ក្នុងពេលមកធ្វើការ រក្សាគម្លាតបុគ្គល អនុវត្តភារកិច្ចដែលមិនតម្រូវឱ្យជួបផ្ទាល់ជាមួយអតិថិជន ឬជួបពាក់ព័ន្ធជាមួយសហសេវិករបស់ខ្លួន ជាដើម។ | • សាមីក្រសួង-ស្ថាប័ន, អង្គភាព, គ្រឹះស្ថាន និងអាជីវកម្ម ដោយសហការ/សម្របសម្រួលជាមួយរដ្ឋបាលសុខាភិបាល |
| • ប្រើប្រាស់ QR Code (STOP Covid-19) ស្កេន នៅពេលចូលក្នុងកន្លែងធ្វើការ/ទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ច៖ ការប្រើប្រាស់ QR Code ផ្តល់សារៈសំខាន់ក្នុងការស្វែងរកករណីកូវីដ-១៩ និងផ្តល់ព័ត៌មានពីស្ថានភាពនៃចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩។ | • សាមីក្រសួង-ស្ថាប័ន, អង្គភាព, គ្រឹះស្ថាន និងអាជីវកម្ម ដាក់ QR Code នៅច្រកចូលទីតាំង<br>• មន្ត្រី បុគ្គលិក កម្មករ និយោជិត អតិថិ-ជនត្រូវទម្លាប់ប្រើប្រាស់ QR Code<br>• អនុគណៈកម្មការបច្ចេកវិទ្យានិងទិន្នន័យ |
| • ពង្រីកការប្រើប្រាស់មធ្យោបាយឌីជីថល និងនវានុវត្ត (Digital and innovative solution) ដើម្បីសម្របវិធានការសុខាភិបាល សំដៅកាត់បន្ថយការជួបប្រាស្រ័យទាក់ទងផ្ទាល់មុខ(ឧ. ឌីជីថលពាណិជ្ជកម្ម-សេវាកម្ម ដូចជា ការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ជាដើម) និងភាពកកកុញ ឬប្រមូលផ្តុំមនុស្សច្រើននៅក្នុងទីកន្លែង/ទីតាំង ជាដើម។ | • សាមីក្រសួង-ស្ថាប័ន, អង្គភាព, គ្រឹះស្ថានអាជីវកម្ម<br>• អនុគណៈកម្មការបច្ចេកវិទ្យានិងទិន្នន័យ |